**TKI0760**

**សម្ភាសន៍ជាមួយឈ្មោះ ទឹម ផល ភេទស្រី អាយុ៥៩ឆ្នាំ**

**មុខងារនៅសម័យខ្មែរក្រហមៈ ជាប្រធាននារីឃុំ**

**សព្វថ្ងៃនៅភូមិសំរោងខាងកើត ឃុំគោកព្រេច ស្រុកគិរីវង់ ខេត្តតាកែវ**

**សម្ភាសន៍ដោយៈ ផេង ពង្សរ៉ាស៊ី**

**០១ៈ៣៨ៈ០៣**

**៤២ទំព័រ**

រ៉ាស៊ី ៈ អ៊ំ! ពួកខ្ញុំនេះមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចខ្ញុំជម្រាបអ៊ំមិញចឹង ខ្ញុំឈ្មោះ រ៉ាស៊ី កញ្ញានេះឈ្មោះ គន្ធី និងវិសាល ហើយម្នាក់ទៀតឈ្មោះ សេងគា ទាំងអស់គ្នានឹងធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ កន្លែងនឹង កន្លែងបោះពុម្ព ស្វែងរកការពិត ។ ហើយសៀវភៅនេះ បោះពុម្ពដោយមានការអនុញ្ញាតិត្រឹមត្រូវ ពីក្រសួងពត៌មានពីរដ្ឋាភិបាលកម្ពុជាយើង ។ ហើយសៀវភៅខាងក្រោមនេះ គឺជាសៀវ ភៅដែលបង្ហាញពីមេដឹកនាំធំៗរបស់ប៉ុលពត មាន៤រូបក្នុងហ្នឹង ។ អ៊ំបើកទៅឃើញ មានឈ្មោះ នួន ជាមានទាំងរូបថត មានទាំងឯកសារពាក់ព័ន្ធមួយចំនួនទៀត ។ ហើយគោលបំណងខាងខ្ញុំមកថ្ងៃនេះគ្រាន់តែចង់ដឹងពីប្រវត្តិរបស់អ៊ំតិចតួច បើអ៊ំដឹងប៉ុណ្ណាប្រាប់ខ្ញុំប៉ុណ្ណឹង ហើយបើសិនអត់ចាំក៏អត់អីដែរ ។ និយាយប្រវត្តិរបស់អ៊ំតាំងពីតូចមក និយាយ រួមតាំងពីតូចរហូតមកដល់ប៉ុណ្ណេះ ។ អ៊ំបានទៅកន្លែងណាខ្លះ? រៀននៅសាលាណា? ឪពុកម្ដាយឈ្មោះអី? ផ្លាស់ប្ដូរទីលំនៅ ពីកន្លែងណាទៅកន្លែងណាខ្លះ? និយាយរួមទៅ គឺប្រវត្តិរបស់អ៊ំផ្ទាល់ដើម្បីឲ្យខ្ញុំយកទៅចងក្រងជាឯកសារប្រវត្តិសាស្រ្ត ទុកឲ្យក្មេងៗជំនាន់ក្រោយបានរៀន ។ ហើយថ្មីៗនេះ មជ្ឈមណ្ឌលកម្ពុជា បានចុះទៅបង្រៀនគ្រូទូទាំងប្រទេស គ្រូប្រវត្តិវិទ្យាទូទាំងប្រទេស ដើម្បីឲ្យពួកគាត់ចេះរបៀបបង្រៀនថា តើត្រូវបង្រៀនអំពីរបបខ្មែរក្រហមហ្នឹងយ៉ាងម៉េច គឺយើងមិនមែនបង្រៀនឲ្យគាត់ចេះបង្រៀនតាមរបៀបគុំគួន របៀបសងសឹកទេ ប៉ុន្តែយើងបង្រៀនឲ្យគាត់ចេះបង្រៀនសិស្សតាមរបៀបផ្សះផ្សា ហើយនឹងការការពារទប់ស្កាត់អំពើប្រល័យពូជសាសន៍ កុំឲ្យកើតឡើងម្ដងទៀត ។ ចឹងបើសិនជាខ្ញុំសុំសម្ភាសន៍អ៊ំ តើអ៊ំមានការអនុញ្ញាតិដែរទេ?

ផល ៈ អត់មានអី ។

រ៉ាស៊ី ៈ អត់អី?

ផល ៖ ចា៎!

រ៉ាស៊ី ៖ ចឹងខ្ញុំសូមចាប់ផ្តើមតែម្តង សុំស្គាល់ឈ្មោះអ៊ំៗឈ្មោះអីដែរ?

ផល ៖ ខ្ញុំឈ្មោះ ទឹម ផល ។

រ៉ាស៊ី ៖ អាយុប៉ុន្មាន?

ផល ៖ អាយុ៥៩ ។

រ៉ាស៊ី ៖ អ៊ំរស់នៅភូមិនេះគេហៅភូមិអី?

ផល ៖ ភូមិសំរោងខាងកើត ។

រ៉ាស៊ី ៖ សំរោងកើត ឃុំអីគេ?

ផល ៖ ឃុំគោកព្រិច ។

រ៉ាស៊ី ៖ ចុះស្រុកកំណើតអ៊ំនៅណាដែរ?

ផល ៖ នៅហ្នឹងម៉ង កើតនៅហ្នឹង ។

រ៉ាស៊ី ៖ អ៊ំមានបងប្អូនប៉ុន្មាននាក់ដែរ?

ផល ៖ មាន៥នាក់ ប៉ុន្តែស្លាប់បាត់អស់ហើយ ។

រ៉ាស៊ី ៖ មានឈ្មោះអ្វីខ្លះទៅ?

ផល ៖ មួយ ទឹម ស្រេង, ទឹម ទូច ។

រ៉ាស៊ី ៖ ស្រេងនឹង ប្រុស(ឬ)ស្រី?

ផល ៖ ស្រីទាំងអស់ហ្នឹង ហើយបានខ្ញុំទឹម ផល ប្អូន ទឹម ភី ហើយមួយទៀត ទឹម សុខចន ។

រ៉ាស៊ី ៖ ស្រីទាំងអស់?

ផល ៖ ស្រីទាំងអស់ ។

រ៉ាស៊ី ៖ ហើយនៅរស់ប៉ុន្មាននាក់ ស្លាប់ប៉ុន្មាននាក់?

ផល ៖ នៅ៣នាក់ ស្លាប់២ ។

រ៉ាស៊ី ៖ ឈ្មោះអីគេ ស្លាប់?

ផល ៖ ស្លាប់ហ្នឹង ទឹម ស្រេង ហើយនឹង ទឹម ទូចហ្នឹង ។

រ៉ាស៊ី ៖ ស្លាប់២នាក់បងៗ?

ផល ៖ ចា៎!

រ៉ាស៊ី ៖ គាត់ស្លាប់ដោយសារមូលហេតុអ្វីដែរ?

ផល ៖ គាត់ ឈឺៗទាំងអស់ ។

វ៉ាស៊ី : ស្លាប់ក្នុងជំនាន់យើងឥឡូវៗនេះ?

ផល : ជំនាន់ឥឡូវនេះមួយ និងជំនាន់ប៉ុលពតមួយ ប៉ុនស្លាប់នឹងទៅនៅខាងស្រុកមោងនោះ ។

វ៉ាស៊ី : ទៅនៅមោងបាត់ដំបង?

ផល : ចា៎!

វ៉ាស៊ី : ហេតុអីបានជាគាត់ទៅនៅហ្នឹង?

ផល : មានអ៊ុំ នៅនឹង ទៅនៅជាមួយគាត់ ។

វ៉ាស៊ី : ស្លាប់ជំនាន់ប៉ុលពត អ៊ុំដឹងថាឆ្នាំណា?

ផល : ដឹងឆ្នាំប៉ុន្មានទេ មិនបានគិត ។

វ៉ាស៊ី : សុទ្ធតែឈឺ?

ផល : ចា៎!

វ៉ាស៊ី : ចុះពីរនាក់ទៀតនេះ សុខចន គាត់នៅរស់នៅណា?

ផល : សុខចននៅកោះធំ ឆ្ងាយដែរ ។

វ៉ាស៊ី : គាត់មានគ្រួសារនៅហ្នឹង?

ផល : មាននៅហ្នឹង ។

វ៉ាស៊ី : ចុះភី?

ផល : នៅភូមិចំបក់មានគ្រួសារនៅចំបក់ ។

វ៉ាស៊ី : មានគ្រួសារទៅនៅជាមួយគ្រួសារ?

ផល : ចា៎!

វ៉ាស៊ី : ខ្មែរយើងតែមនុស្សស្រីមានគ្រួសារខាងគេមកនៅខាងយើង?

ផល : ស្រេចតែមានកន្លែងនៅអានឹង ។

វ៉ាស៊ី : ភីគាត់មានកូនចៅប៉ុន្មាននាក់?

ផល : កូន៧ តែខ្ញុំអត់ទេ ។

វ៉ាស៊ី : អ៊ុំអត់ទេ?

ផល : ចា៎!

វ៉ាស៊ី : ចុះឪពុកម្ដាយ?

ផល : ឪពុកឈ្មោះ ទឹម អ៊ិន ម្ដាយឈ្មោះ ទៀង សុគ ។

វ៉ាស៊ី : គាត់នៅរស់ទាំងពីរឬគាត់ខូច?

ផល ៖ ស្ងាប់ ។

រ៉ាស៊ី ៖ គាត់ខូចជំនាន់យើងឥឡូវ?

ផល ៖ ចា៎! ខ្ញុំត្រឡប់មកវិញហើយ ។

រ៉ាស៊ី ៖ ចឹងនៅនេះនៅតែ២នាក់?

ផល ៖ ចា៎!

រ៉ាស៊ី ៖ នៅ ភី ហើយអ៊ំមួយ?

ផល ៖ ចា៎!

រ៉ាស៊ី ៖ គាត់មានដែលមកលេងអ៊ំ?

ផល ៖ មកតែចឹង ។

រ៉ាស៊ី ៖ ចឹងខ្ញុំចង់សួរអ៊ំកាលអ៊ំនៅតូចៗ អ៊ំបានរៀន?

ផល ៖ ខ្ញុំបានរៀន ។

រ៉ាស៊ី ៖ រៀននៅណា?

ផល ៖ រៀននៅសាលាព្រៃជើង ។

រ៉ាស៊ី ៖ ព្រៃជើងឈ្មោះភូមិ?

ផល ៖ វត្តនៅខាងជើងម៉ង ។

រ៉ាស៊ី ៖ កាលនឹងផ្ទះអ៊ំនៅនឹងដែរ?

ផល ៖ ចា៎!នៅនឹងដែរ ។

រ៉ាស៊ី ៖ ចឹងដើរទៅរៀនឆ្ងាយដែរ?

ផល ៖ ដើរទៅ កាលជំនាន់នឹង សុទ្ធតែដើរ ។

រ៉ាស៊ី ៖ អ៊ំរៀនបានថ្នាក់ទីប៉ុន្មាន?

ផល ៖ កាលនឹងគេហៅទី៩ៗ អត់ទៅរៀននៅសុបិន្ត អត់មានកងអីជិះអត់ទៅ ។

រ៉ាស៊ី ៖ នៅសុបិន្តថ្នាក់ធំជាងនេះ?

ផល ៖ ចា៎! ធំជាង ចូលទី៨ឡើងទៅ ។

រ៉ាស៊ី ៖ ហើយកាលនឹងអ៊ំភី មករៀនជាមួយអ៊ំដែរ?

ផល ៖ ចា៎! ទីប៉ុន្មានទេ រៀនក្រោយខ្ញុំៗឈប់មុន ។

រ៉ាស៊ី ៖ ម៉េចបានឈប់?

ផល ៖ វា ម៉ែឪទាល់ក្រ តដៃតជើងហើយវាអត់ទៅ វាអត់មានដូចថាទៅរៀនឆ្ងាយចឹង វាពិបាក ដើរ ឈប់ទៅ ។

ភ៊ាស៊ី ៖ អ៊ំឈប់នៅឆ្នាំណា?

ផល ៖ ឆ្នាំប៉ុន្មានទេ ចូលរៀនឆ្នាំ៦៣ ។

ភ៊ាស៊ី ៖ ចូល៦៣?

ផល ៖ ចាំ!

ភ៊ាស៊ី ៖ ចូល៦៣នឹង ចូលថ្នាក់ទីប៉ុន្មាន ទី១២?

ផល ៖ ទី១២ ។

ភ៊ាស៊ី ៖ ១២ ១១ ១០ ៩ ៣ឆ្នាំ មីងរៀនបាន៣ឆ្នាំ?

ផល ៖ ចាំ! រៀន៣ឆ្នាំ ។

ភ៊ាស៊ី ៖ ចឹង៦៦?

ផល ៖ ចាំ!

ភ៊ាស៊ី ៖ ចុះឈប់រៀនអ៊ំទៅណាទៀត?

ផល ៖ នៅផ្ទះនឹង ។

ភ៊ាស៊ី ៖ ធ្វើអីទៅ?

ផល ៖ គ្មានធ្វើអី ធ្វើតែស្រែ ធ្វើតែអីនៅជាមួយម៉ែឪនឹង មានធ្វើរកធ្វើស្រែចំការ ។

ភ៊ាស៊ី ៖ ចុះបង១២នាក់ទៀតនោះ ស្រី?

ផល ៖ គាត់មានគ្រួសារ ។

ភ៊ាស៊ី ៖ ចុះអ៊ំធ្វើការនៅនឹង រហូតទៅដល់ពេលសម័យរដ្ឋប្រហារ អ៊ំដឹងទេ?

ផល ៖ រដ្ឋប្រហារដឹង កាលឆ្នាំ៧០នឹងរដ្ឋប្រហារ ។

ភ៊ាស៊ី ៖ កាលឆ្នាំ៧០ រដ្ឋប្រហារនឹង អ៊ំអាយុប៉ុន្មាន?

ផល ៖ អាយុប៉ុន្មាន អាយុ១៩ ចុះកើត៥១ ដល់ឆ្នាំ៧០ ។

ភ៊ាស៊ី ៖ អ៊ំកើត៥១?

ផល ៖ ចាំ! ១៩នឹងរដ្ឋប្រហារហើយ ខ្មែរក្រហមចុះមក ។

ភ៊ាស៊ី ៖ ហើយកាលនឹងអ៊ំមានគ្រួសារនៅ?

ផល ៖ នៅ ។

ភ៊ាស៊ី ៖ ពេលណាអ៊ំមានគ្រួសារ?

ផល :	ដល់អាយុ២៦ ជំនាន់ប៉ុលពត ដែលប្តេជ្ញានឹង ។

វ៉ាស៊ី :	ចឹងអ៊ីការជំនាន់ប៉ុល ពត?

ផល :	ប្តេជ្ញាប៉ុលពតនឹងម្តង បាត់ទៅ ។

វ៉ាស៊ី :	ខ្ញុំនិយាយពីមុនរដ្ឋប្រហារ តើតំបន់នៅក្នុងភូមិនេះ មានខ្មែរក្រហមចូលនៅ?

ផល :	មុនរដ្ឋប្រហារគ្មានទេ ។

វ៉ាស៊ី :	អត់មានទេ?

ផល :	ចា៎!

វ៉ាស៊ី :	គេហៅខ្មែររំដោះកាលនោះ?

ផល :	រដ្ឋប្រហារនឹងគេហៅស៊្ទីរណសិរ្សម៉េចនោះ ។

វ៉ាស៊ី :	បាទ! ហ្នឹងហើយ ក្រុមរណសិរ្ស គេហៅរណសិរ្សស្ទីទេ ខ្ញុំភ្លេចដែរ?

ផល :	រណសិរ្សរួប ។

វ៉ាស៊ី :	រួបរួមជាតិ អានឹងក្រោយទេ ។

ផល :	ដឹងស្ទីទេ ខ្ញុំមិនសូវចាំ ។

វ៉ាស៊ី :	ចឹងបានក្រោយរដ្ឋប្រហារបានមានខ្មែរក្រហម?

ផល :	ចា៎! ដល់រដ្ឋប្រហារហើយ ដូចមានៗរណសិរ្សស្ទីបង្រួបបង្រួមជាតិចឹង អានឹងគេចុះមក ខ្ញុំក៏ចូលទៅជាមួយគេដែរ ។

វ៉ាស៊ី :	មីងចូលទៅជាមួយគេដែរ?

ផល :	ចា៎!

វ៉ាស៊ី :	ចូលនឹងចូលម៉េច?

ផល :	ចូលទៅដើរធ្វើការតាមភូមិចេះតែដើរតាមគេទៅ ។

វ៉ាស៊ី :	កាលហ្នឹងគេហៅចូលបដិវត្តន៍?

ផល :	ចា៎! ចូលបដិវត្ត ។

វ៉ាស៊ី :	ឆ្នាំណា?

ផល :	អាហ្នឹង៧០ប៉ុន្មាន ៧១, ៧២ហ្នឹង ៧១ ។

វ៉ាស៊ី :	ចូលតាំងពី៧១មក?

ផល :	ចា៎!

វ៉ាស៊ី :	កាលហ្នឹងអ្នកណាគេជាអ្នកនាំអ៊ំចូល?

ផល ៖ កាលនឹងគេមានមានមេឃុំ មេអីគេ ។

វ៉ាស៊ី ៖ គេអ្នកឃោសនា?

ផល ៖ ចាំ!

វ៉ាស៊ី ៖ មេឃុំមានឈ្មោះអីទៅ?

ផល ៖ កាលហ្នឹងតាអឹមប្ដីយាយយ៉េមហ្នឹង តាអ៊ឹមនឹង មិនដឹងតាគាត់ឈ្មោះអីទេ នៅចំបក់ហ្នឹង តាអ៊ឹមនឹង កាលនឹងមេឃុំ ។

វ៉ាស៊ី ៖ មេឃុំគោព្រៃចនឹងដែរ?

ផល ៖ មេឃុំតំណាង ខ្មែរក្រហមនឹង ឃុំគោកព្រៃចនឹង ។

វ៉ាស៊ី ៖ កាលហ្នឹងពេលដែលអ៊ំចូលទៅហ្នឹង អ៊ំចូលតែម្នាក់ឯង ឬក៏មានគេអ្នកផ្សេងទៀត ក្នុងភូមិចូលដែរ?

ផល ៖ មានគេនៅក្នុងភូមិនឹង ២នាក់ទេ ។

វ៉ាស៊ី ៖ អ៊ំចូលតែ២នាក់?

ផល ៖ ចាំ! ចូលក្នុងភូមិនឹង២នាក់ទៅ ឯភូមិផ្សេងមានដែរ ។

វ៉ាស៊ី ៖ មានភូមិគេផ្សេងៗ?

ផល ៖ ចាំ!មានគេផ្សេងៗដែរ ។

វ៉ាស៊ី ៖ គាត់នឹងនៅរស់ទេ?

ផល ៖ គាត់នៅប៉ុននៅស្រុកគាត់ កំណាប់ ។

វ៉ាស៊ី ៖ អូ! នៅឃុំកំណាប់?

ផល ៖ ចាំ! ចូល២នាក់នឹងនៅនឹងភូមិយើងទៅ២នាក់ ។

វ៉ាស៊ី ៖ ហេតុម៉េបានជាម៉ាភូមិចូលតែ២នាក់ចឹង?

ផល ៖ ចូលតែ២នាក់ចឹង ទៅតែ២ចឹង ។

វ៉ាស៊ី ៖ គេរើសៗយ៉ាងម៉េច របៀបថាគេរើសឲ្យចូល?

ផល ៖ ស្រេចស្ម័គ្រចិត្ត ។

វ៉ាស៊ី ៖ ចឹងអ្នកផ្សេងទៀត អត់ស្ម័គ្រចិត្តទេ?

ផល ៖ អ្នកផ្សេងទៀតគេនៅជាមួយម៉ែឪគេទៅ ខ្លាចរត់ ខ្លាចអីទៅ បែកម៉ែ បែកឪទៅ ។

វ៉ាស៊ី ៖ ចឹងមូលហេតុអីបានជាអ៊ំស្ម័គ្រចិត្តចូល?

ផល : គេៗឃោសនាប្រាប់យើងថាចូលទៅបំរើជាតិ ដើម្បីដោះឲ្យរួចផុតពីការជិះជាន់ ពួកវណ្ណៈជិះជាន់ៗ ហើយយើង តែគេឃោសនាទៅយើងទៅតាមគេ យើងចេះទៅនឹងគេទៅ ។

រ៉ាស៊ី : ហើយដល់ពេលចូលដំបូងចឹង គេឲ្យទៅណា?

ផល : នៅដើរតាមគេចឹងទៅ គេទៅប្រជុំនៅណាហៅ ប្រជាជនទៅប្រជុំនៅណា យើងទៅតាមគេចឹងទៅ ។

រ៉ាស៊ី : មានប្រជុំចឹងដែរ?

ផល : ចា៎!

រ៉ាស៊ី : ចុះក្រៅពីប្រជុំ ធ្វើអីទៀត?

ផល : ក្រៅពីប្រជុំ វាអត់មានធ្វើអីក្រៅពីប្រជុំរៀនសូត្រនឹងទេគ្មាននៅ ហើយយើងក៏មិនដឹងថាទៅឯណាទៀត គេក៏ឡើងទៅប្រជុំណាទៀតទៅ យើងនៅតូចៗនៅកន្លែងនឹងទៅ ។

រ៉ាស៊ី : កាលហ្នឹងអ៊ំថាទៅប្រជុំជាមួយគេ ទៅជាមួយណាគេដែរ?

ផល : ប្រជុំជាមួយគេអ្នកធ្វើការមុនៗគេហៅយើងទៅ ។

រ៉ាស៊ី : ស្គាល់ឈ្មោះណាខ្លះ?

ផល : ដូនកាលអ្នកមកពីស្រុកត្រាំកក់ មកពីអង្គរជ័យ គេអ្នកធ្វើការគេមុនគេដូចថារៀមច្បងយើងចឹង អានឹងវាមកមុននឹង ។

រ៉ាស៊ី : ចឹងអ្នកដែលធ្វើការនៅក្នុងភូមិហ្នឹង មិនមែនអ្នករស់នៅក្នុងនឹងទេ?

ផល : មិនមែនអ្នកស្រុកនឹងទេ ចា៎! អ្នកស្រុកហ្នឹងតែមេឃុំមួយទេ ។

រ៉ាស៊ី : ចឹងអ្នកដែលអ៊ំទៅប្រជុំជាមួយនឹង ធំជាងមេឃុំទៀត ឋានៈធំជាងមេឃុំទៀត?

ផល : ចា៎! គេធំជាង ។

រ៉ាស៊ី : គេឋានៈអីៗ?

ផល : កាលហ្នឹងគេថាគេជាប្រធានយុវជនអីចឹង ។

រ៉ាស៊ី : ស្គាល់ឈ្មោះទេ អ៊ំ?

ផល : យូរហើយ ភ្លេចអស់ហើយឈ្មោះៗ ស៊ឹម, ឈ្មោះ វណ្ណ ហើយនឹងស្អីខ្លះទៀតទេច្រើន វាយូរពេកទៅហើយ ភ្លេច ចាំស៊ឹម ហើយវណ្ណ ។

រ៉ាស៊ី : ចាំស៊ឹម ហើយវណ្ណ ស្រីៗទាំងអស់ឬក៏ប្រុស?

ផល : ប្រុសទាំងអស់ មកមុនដំបូងហ្នឹង ប្រុសទាំងអស់ ។

រ៉ាស៊ី : ហើយគាត់ហ្នឹងយ៉ាងម៉េចដែរ កាលហ្នឹងគាត់អាយុប៉ុន្មាន បងមីងច្រើន?

ផល ៈ	អត់ៗដឹងទេ អាយុ អត់ដឹង ។

ភ៉ាស៊ី ៈ	ប៉ុនរៀនចំណាស់ជាងមីង ឬក៏ក្មេង?

ផល ៈ	ចាំ! ចាស់ជាង ។

ភ៉ាស៊ី ៈ	ហើយគាត់មើលទៅអត្តចរិក អាកប្បកិរិយាគាត់យ៉ាងម៉េចដែរ ពេលនឹង?

ផល ៈ	កាលជំនាន់ហ្នឹងគឺ ដើរធ្វើការនឹងទៅដូចជាស្លូតបូតៗ អត់មានកាចមានអីធ្វើទុក្ខបុកម្និញប្រជាជនអីអត់ ប៉ុនខ្ញុំចេះទៅតាមគេទៅ ។

ភ៉ាស៊ី ៈ	ហ្នឹងឆ្នាំ៧១នឹង?

ផល ៈ	ចាំ! ៧១ ។

ភ៉ាស៊ី ៈ	ហើយអ៊ំធ្វើការជាមួយពួកគាត់ហ្នឹង បានប៉ុន្មានឆ្នាំទៅ?

ផល ៈ	ខ្ញុំធ្វើការជាមួយពួកហ្នឹងបានប្រហែលជា១ឆ្នាំ កាលហ្នឹងវាមានអាធីវគីមកប្លោងដាក់ត្រូវរបួសឪខ្ញុំៗ ឡើងទៅលើទៅ ខ្ញុំទៅលើដែរទៅ ។ អង្គការគេលើនឹងក៏គេទទួលឲ្យ ចូលនៅក្នុងមន្ទីរគេទៀត ។

ភ៉ាស៊ី ៈ	គាត់របួសហ្នឹង របួសដោយសារគ្រាប់ប្លោងនឹង?

ផល ៈ	ចាំ!

ភ៉ាស៊ី ៈ	ឆ្នាំណាទៅអ៊ំ?

ផល ៈ	ឆ្នាំ៧១ហ្នឹង ។

ភ៉ាស៊ី ៈ	ក្នុង៧១ដែរ?

ផល ៈ	ចាំ!

ភ៉ាស៊ី ៈ	៧១មានពួកធីវគីមកទម្លាក់គ្រាប់បែក?

ផល ៈ	ចាំ! មកប្លោង ។

ភ៉ាស៊ី ៈ	ប្លោង មិនមែន កាប៉ាល់ហោះមកទម្លាក់?

ផល ៈ	ចាំ! ប្លោងមុន បានទម្លាក់ក្រោយ ប្លោងដាក់ភ្នំ ។

ភ៉ាស៊ី ៈ	ពួកធីវគីហ្នឹង ពួកខាងណាអ៊ំ?

ផល ៈ	ពួកយួន ។

ភ៉ាស៊ី ៈ	យួនហ្នឹង វាមានយួនខាងលន់ នល់ និងយួនខាងខ្មែរក្រហម?

ផល ៈ	យួន គេថាយួនអាធីវគីៗ ដឹងយួនណាខ្លះ ។

ភ៉ាស៊ី ៈ	ហើយមកក្រោយទៀតហ្នឹង អ៊ំទៅណាឆ្នាំ៧២, ៧៣?

ផល ៖ ដល់ខ្ញុំទៅនៅឯលើនឹង គេឲ្យខ្ញុំធ្វើទ័ព ។

រ៉ាស៊ី ៖ នៅលើនៅណា?

ផល ៖ នៅស្រុកលើ ស្រុកត្រាំកក់ហ្នឹង ។

រ៉ាស៊ី ៖ អូ! ដូរទៅត្រាំកក់ ឆ្នាំណា?

ផល ៖ ចា៎! គេកន្លែងនឹង គេធ្វើមានមន្ទីរគេ មានមន្ទីរនារីនៅខាងនោះ ។

រ៉ាស៊ី ៖ កាលហ្នឹង គេហៅស្រុកប៉ុន្មានអ៊ី?

ផល ៖ ស្រុក១០៥ ស្រុកត្រាំកក់នឹងគេហៅ១០៥ ហើយគេហៅចូលមន្ទីរនឹងមន្ទីរ១ ១៥០ ។

រ៉ាស៊ី ៖ មន្ទីរ១៥០នឹងមន្ទីរអីគេ?

ផល ៖ មន្ទីរ១៥០ចឹង ១៥០ខ មន្ទីរនឹង១៥០ គេនៅមាននារីៗអង្គការនារីគេនៅហ្នឹង ដល់ ខ្ញុំនៅបានប៉ុន្មានខែគេឲ្យចេញ ។

រ៉ាស៊ី ៖ ហ្នឹងពេលដែលអ៊ីចេញពីនេះទៅ ឆ្នាំប៉ុន្មាន៧២ ឬ៧១ដដែរ?

ផល ៖ ៧១ ។

រ៉ាស៊ី ៖ ខែណាអ៊ី?

ផល ៖ ខែ មិនចាំទេ ។

រ៉ាស៊ី ៖ ខែយើងរបៀបខែភ្លៀង ខែរាំង ឬខែស្ងួត?

ផល ៖ ខែភ្លៀង ខែផ្លែឈើទុំ ខែទ្រាដូចខែ១០ ១១នឹង ។

រ៉ាស៊ី ៖ ហើយកាលហ្នឹងអ៊ីទៅដោយសារ?

ផល ៖ យកឲ្យទៅត្រូវរបួស ក៏គេយកទៅលើចូលមន្ទីរពេទ្យគេលើនោះ ឪខ្ញុំគេយកដាក់ពេទ្យទៅ ខ្ញុំឲ្យចូលមន្ទីរនារីទៅ ។

រ៉ាស៊ី ៖ ចូលមន្ទីរនារី ក៏នៅនឹងទៅ?

ផល ៖ នៅនឹងបានតិចនឹង ខ្ញុំនៅមន្ទីរនឹងមិនបានយូរទេ ខ្ញុំដល់ពេលនេះគេឲ្យ គេរើសខ្ញុំចូលកង ទ័ព ។

រ៉ាស៊ី ៖ មន្ទីរហ្នឹង ការងាររបស់មន្ទីរហ្នឹង គេឲ្យធ្វើអ្វីខ្លះ?

ផល ៖ ការងាររបស់មន្ទីរហ្នឹង គេមាននៅកន្លែងគេនឹងមានដាំដំណាំអីដែរហ្នឹង ប៉ុន្តែខ្ញុំនៅមិនបាន យូរកន្លែងមន្ទីរនឹង មានដាំបន្លែដាំស្ពៃ ។

រ៉ាស៊ី ៖ កាលហ្នឹងមីងធ្វើអីគេ?

ផល ៖ គ្មានធ្វើអីទេ នៅតែជាមួយគេនឹង គ្មានធ្វើស្អីធំដុំ ។ ប៉ុនដល់នៅបានប៉ុន្មាន គេឲ្យខ្ញុំទៅធ្វើការ នៅឃុំខ្ពបរុន ជាប្រធាននារីឃុំ ។

រ៉ាស៊ី ៖ ប្រធាននារីឃុំឆ្នាំណា? ៖

ផល ៖ ក្នុង៧១នឹងដដែល ៧១ ចូល៧២ ។

រ៉ាស៊ី ៖ ចុង៧១?

ផល ៖ អឺ!ចុង៧១ ដើម៧២នឹង ។

រ៉ាស៊ី ៖ ខែរងារនៅ?

ផល ៖ ចា៎! ខែរងារហើយ ។

រ៉ាស៊ី ៖ ចឹងខែរងារយើងខែប៉ុន្មាន ខែ១១ ខែ១២? គេមើលឃើញមឹងធ្វើការយ៉ាងម៉េច បានគេដំឡើងឋានៈឲ្យមីងចឹង?

ផល ៖ ខ្ញុំក៏មិនដឹងដែរ ខ្ញុំតែគេឲ្យធ្វើស្អី ខ្ញុំចេះតែធ្វើតាមគេចឹង ។

រ៉ាស៊ី ៖ ខ្ពករុន?

ផល ៖ ចា៎! ឃុំខ្ពបរុន ភូមិត្រពាំងអណ្ដើក ។

រ៉ាស៊ី ៖ ឃុំខ្ពបរុន ភូមិត្រពាំងអណ្ដើក? ហើយកាលហ្នឹងនៅនឹង អ្នកណាគេជាប្រធានឃុំ គណៈឃុំ?

ផល ៖ ប្រធានឃុំឈ្មោះ តាញ៉ែប ស្លាប់បាត់ហើយ ។

រ៉ាស៊ី ៖ ញ៉ែបហ្នឹង ថាប្រធានឃុំនៅកំពែងដែរ?

ផល ៖ តាអ៊ឹម ។

រ៉ាស៊ី ៖ នៅតាអ៊ឹម?

ផល ៖ ញ៉ែបមួយទៀត ឈប់ចាំខ្ញុំនិយាយកាលឆ្នាំនឹងតាញ៉ែបនឹងនៅឃុំខ្ពបរុន នៅធ្វើប្រធាននៅនឹង ។ ដល់ពេលខ្ញុំចេញ គេហៅខ្ញុំទៅកងទ័ពទៅ បានគេឲ្យតាញ៉ែបហ្នឹងមកនៅឃុំកំពែង ។

រ៉ាស៊ី ៖ ហ្នឹងបែកភ្នំពេញនៅ បែក៧៥នៅ?

ផល ៖ តាញ៉ែបហ្នឹងមកនោះ ខ្ញុំមកជួបតាញ៉ែបនៅកំពែងនឹង៧៤ ។

រ៉ាស៊ី ៖ ៧៤?

ផល ៖ ចា៎!

រ៉ាស៊ី ៖ បាទ! ចឹងនៅដើម៧២ អ៊ំឡើងជាប្រធាន?

ផល : ចូលកន្លែងនារីនឹងបានប៉ុន្មានខែ ខ្ញុំនៅអត់បានយូរ កន្លែងឃុំខ្ពបរុននឹង ខែប៉ុន្មានទៀតគេហៅខ្ញុំទៅកងទ័ព ខ្ញុំមិនដឹងខែប៉ុន្មាន ។

វ៉ាស៊ី : ពេលនៅនឹង នារីនៅក្នុងឃុំនឹងប៉ុន្មាននាក់ ដែលអ៊ំគ្រប់គ្រង នៅខ្ពបរុន?

ផល : អត់មានឃុំវនារីនៅក្នុងអង្គភាពទេ មានតែខ្ញុំមួយទេ ។

វ៉ាស៊ី : ចឹងម៉េចបានជាមានប្រធាននារីអីចឹង?

ផល : មានប្រធាននារីឃុំ ។

វ៉ាស៊ី : មានប្រធាននារីឃុំ ប៉ុន្តែអត់មាននារីគ្រប់គ្រង?

ផល : នារីក្នុងហ្នឹងអត់មានក្នុងគណៈនារីនៅក្នុងហ្នឹងគឺ គេចេញពីកន្លែងមន្ទីរហ្នឹងទៅគ្រប់គ្រងឃុំហ្នឹងម៉ង ព្រោះមន្ទីរហ្នឹងវានៅជិត ។

វ៉ាស៊ី : ចឹងអ៊ំទៅនេះមិនមែនគ្រប់គ្រងតែនារីទេ គ្រប់គ្រងទាំងបុរស និងនារី?

ផល : ផ្នែកខាងនារី អត់មានបុរសៗ គេមានផ្នែកគេ ។ បុរសគេមានបុរស យុវជន គេមានយុវជន ។

វ៉ាស៊ី : កាលនោះអ្នកណាគេជាប្រធានយុវជន?

ផល : ឈ្មោះ គាត់នឹងដឹងឈ្មោះអី ឈ្មោះ សាម ប៉ុនមិនដឹងនៅស្រុកណា សាម នឹង ដឹងនៅត្រាំកក់ ហើយក៏មិនដឹងនៅស្រុកណាទេ ខ្ញុំក៏មិនបានគ្រាន់តែស្គាល់ឈ្មោះ សាម ។

វ៉ាស៊ី : ចឹងការងាររបស់ប្រធាននារី ការងាររបស់ប្រធានយុវជនមានអីខ្លះទៅ?

ផល : ដើរប្រជុំពីរឿងសីលធម៌ ពីរឿងលះបង់កម្មសិទ្ធិអីនឹង ។

វ៉ាស៊ី : សីលធម៌ហ្នឹងប្រជុំយ៉ាងម៉េចទៅ?

ផល : ប្រជុំថាយើងកុំឲ្យភ្លើតភ្លើន កុំឲ្យនៅមានកម្មសិទ្ធិក្រាស់ ឲ្យយើងសុខចិត្តលះបង់ទៅបំរើជាតិអីចឹង ។

វ៉ាស៊ី : ហើយអ៊ំឡើងនិយាយប្រាប់គេចឹងទៅ?

ផល : ចា៎!

វ៉ាស៊ី : ចុះពេលដែលប្រជុំហើយចឹង មានដែលអ្នកអនុវត្តល្មើសនឹងអ្វីដែលប្រជុំប្រាប់នឹងទេ ដូចថាហាមមិនឲ្យមានសីលធម៌ស្រាប់តែមានខូចសីលធម៌?

ផល : នៅកន្លែងហ្នឹង អត់ទាន់មាន ព្រោះខ្ញុំនៅតិចខែដែរ ។

វ៉ាស៊ី : ដូចនៅអំឡុងពេលអ៊ំនៅអត់ទាន់មាន ។

ផល : វាអត់ឃើញមានស្អី ។

វ៉ាស៊ី ៖ ចុះបើសិនជាឧបមាថា អ៊ំប្រជុំប្រាប់ចឹងហើយ ស្រាប់តែមានរឿងកើតឡើងថា មានខូច សីលធម៌ជាមួយគ្នាចឹង តើត្រូវធ្វើយ៉ាងម៉េចចំពោះពួកគាត់?

ផល ៖ អាហ្នឹងអារឿងការងារអស់ទាំងអស់ ដល់ពេលមានរឿងមានហេតុអីធំនៅលើប្រធានឃុំជាអ្នកសម្រេច ។

វ៉ាស៊ី ៖ ប៉ុន្តែអ្នកទាំងអស់ហ្នឹងនៅក្រោមបញ្ជាគ្រប់គ្រងរបស់អ៊ំ ហើយនឹងប្រធានកងបុរស ប្រធានយុវជន ។ ចឹងតែទាល់តែអ៊ំរាយការណ៍ទៅ ខាងលើបានខាងឃុំនឹងគេដឹង?

ផល ៖ ចា៎!

វ៉ាស៊ី ៖ ចឹងការងារគឺថា រាល់ការងាររបស់យុវជនយុវនារីត្រូវឆ្លងកាត់មកអ៊ំសិន បានអ៊ំរាយការណ៍ទៅឃុំ បាន?

ផល ៖ យុវជនផ្នែកយុវជនផ្សេង ខ្ញុំដឹងតែផ្នែកនារីចឹងណា ។

វ៉ាស៊ី ៖ គ្រប់គ្រងតែនារីចឹងទៅ?

ផល ៖ ចា៎!

វ៉ាស៊ី ៖ គេឲ្យធ្វើការជាមួយគ្នាទេ នារី យុវជន?

ផល ៖ នារី យុវជន ធ្វើការជាមួយគ្នាហ្នឹង ប៉ុនថាវាមានផ្នែក យើងគ្រប់គ្រងនារីទៅ គេយុវជនគ្រប់គ្រងយុវជនទៅ ពេលដែលទៅប្រជុំយើងទៅជាមួយគ្នាទៅ ។

វ៉ាស៊ី ៖ នៅក្នុងមួយខែប្រជុំប៉ុន្មានដង?

ផល ៖ មិនទៀងទេ ។

វ៉ាស៊ី ៖ វាអាស្រ័យទៅលើអីទៅអ៊ំ?

ផល ៖ គេទៅធ្វើការតាមភូមិយប់ថ្ងៃនេះទៅភូមិនេះ ថ្ងៃនោះទៅភូមិនោះចឹងទៅ មិនទៀង ។

វ៉ាស៊ី ៖ អ៊ំធ្វើតែនៅក្នុងឃុំខ្ពបរុន អត់មានទៅឃុំផ្សេងៗ?

ផល ៖ ឃុំខ្ពបរុនហ្នឹងហើយ ខ្ញុំទៅកងទ័ព ។

វ៉ាស៊ី ៖ នៅឆ្នាំណា?

ផល ៖ ៧២ ៗ ខ្ញុំទៅកងទ័ព ។

វ៉ាស៊ី ៖ ម៉េចបានគេដកអ៊ំទៅកងទ័ពវិញ?

ផល ៖ ខ្ញុំក៏មិនដឹងដែរដឹងគេឃើញម៉េចបានគេឲ្យចូលៗកងទ័ពនោះ ឃើញខ្ញុំឃើញយ៉ាងម៉េចបានគេឲ្យទៅ ខ្ញុំក៏មិនដឹងដែរ ។

វ៉ាស៊ី ៖ អ្នកណាគេអ្នកចាត់អ៊ំ?

ផល ៖ អនុគណៈគេហៅថាប្រធាននារីតំបន់គេហ្នឹង ។

រ៉ាស៊ី ៖ ឈ្មោះអីគេ?

ផល ៖ ឈ្មោះ យឿន ហើយនឹងគណៈតំបន់គេ ។

រ៉ាស៊ី ៖ ឈ្មោះគាត់នេះ ជាប្រធាននារីតំបន់?

ផល ៖ ចា៎!

រ៉ាស៊ី ៖ មិនមែនប្រធានកងចល័ត?

ផល ៖ ប្រធានតំបន់ ។

រ៉ាស៊ី ៖ ប្រធានតំបន់ម៉ង ឬប្រធាននារីតំបន់?

ផល ៖ ប្រធាននារីតំបន់ ប្រធានតំបន់នោះ ឯកភាពពីប្រធាននារីតំបន់នឹងបានទៅចូលដល់កន្លែងប្រធានតំបន់នឹង អានឹងគេចាត់តាំងខ្ញុំទៅ ។

រ៉ាស៊ី ៖ តំបន់ៗប៉ុន្មានដែរ?

ផល ៖ តំបន់១៣ ។

រ៉ាស៊ី ៖ ចុះប្រធានតំបន់១៣ម៉ង ឈ្មោះអី?

ផល ៖ ឈ្មោះគេហៅក្រៅ សោម ប៉ុនដល់ក្នុងប្រវត្តិរូបក្នុងនេះឈ្មោះ ថន ។

រ៉ាស៊ី ៖ ឈ្មោះអីថន?

ផល ៖ មិនចាំ អត់ចាំត្រកូល ។

រ៉ាស៊ី ៖ គាត់មកពីខាងណាវិញ?

ផល ៖ ថន នឹង មិនដឹងមកពីខេត្តណាទេមកនៅខេត្តតាកែវ មិនដឹងមកពីខេត្តណា ហើយយឿននឹងមកពីខេត្តកំពង់ឆ្នាំង ។ ឈ្មោះ ថន ហ្នឹងមិនដឹងមកពីខេត្តណា ព្រោះគេធំ ខ្ញុំក៏មិនហ៊ានដេញដោល ។

រ៉ាស៊ី ៖ ចុះយឿនហ្នឹង ប្រធាននារីតំបន់ តាំងពីឆ្នាំ៧២មក ឬក៏មុននឹងទៀត?

ផល ៖ ខ្ញុំទៅហ្នឹងឃើញនៅហ្នឹងហើយ ។

រ៉ាស៊ី ៖ ពេលអ៊ំទៅ៧២នឹង ឃើញនៅនឹង?

ផល ៖ ចា៎! ឈ្មោះនឹងវាមានពីរនារីនឹង មួយជាតិឈ្មោះជាតិ អូ!មកនឹង៧២ បងយឿននឹងហ្នឹងមក៧២ ។ មុនដំបូង ជាតិហ្នឹង ។

រ៉ាស៊ី ៖ ហើយម៉េចបានជាតិ ធ្លាក់វិញ?

ផល ៈ អត់ធ្លាក់ទេ មិនធ្លាក់នៅគ្រប់គ្រងនៅហ្នឹងដដែល នៅប្រធាននឹងដដែល ប៉ុនគេដាក់ឲ្យមក
បន្ថែមមក៧២ ។ មកពីរៀនសាលាភូមិភាគ ។

ភ៉ាស៊ី ៈ អូ! មកពីសាលាភូមិភាគរបស់តាម៉ុក?

ផល ៈ ចា៎! មកពីរៀនសាលាតាម៉ុកនោះឆ្នាំ៧២ ។

ភ៉ាស៊ី ៈ កាលហ្នឹង អ៊ំចូលទៅធ្វើទាហាន?

ផល ៈ ចា៎! កងទ័ព ។

ភ៉ាស៊ី ៈ ទាហានធ្វើនៅកងណា?

ផល ៈ កងនារីនឹងគេហៅកង២១ ។

ភ៉ាស៊ី ៈ កង២១នៅក្នុងកងពលធំ ឬកងវរៈសេនាតូច?

ផល ៈ កងអនុសេនាធំ២១ ។

ភ៉ាស៊ី ៈ កង២១ហ្នឹង គេហៅកងអនុសេនាធំ?

ផល ៈ ចា៎! កងអនុសេនាធំ២១ ។

ភ៉ាស៊ី ៈ ចុះវរៈសេនាតូចប៉ុន្មាន?

ផល ៈ វរៈសេនាតូច គេហៅវរសេនាតូច៨ ។

ភ៉ាស៊ី ៈ វរៈសេនាធំ?

ផល ៈ វរៈសេនាធំដឹងប៉ុន្មានទេ ខ្ញុំអត់ដឹង ។

ភ៉ាស៊ី ៈ កងពលប៉ុន្មាន?

ផល ៈ មិនដឹងពលនោះទៀត ប៉ុនដឹងថានៅតំបន់១៣ ។

ភ៉ាស៊ី ៈ នៅក្នុងតំបន់១៣ ទីតាំងនៅណាត្រង់ណា?

ផល ៈ នៅតាកែវ ។

ភ៉ាស៊ី ៈ នៅទីរួមខេត្តតាកែវ ឬក៏នៅ?

ផល ៈ នៅ មិននៅក្នុងតាកែវទេ នៅខាងៗ ។

ភ៉ាស៊ី ៈ នៅខាងៗតាកែវ?

ផល ៈ ចា៎!

ភ៉ាស៊ី ៈ អាចនៅម្តុំត្រង់ណា?

ផល ៈ ម្តុំ និយាយរួមជុំវិញខេត្តតាកែវ ជុំវិញទីក្រុងខេត្តតាកែវនឹងម៉ង ។

ភ៉ាស៊ី ៈ ហើយតួនាទីធ្វើអី តួនាទីក្នុងកងអនុសេនាធំទី១?

ផល ៖ មុនដំបូងខ្ញុំបញ្ជាការកងអនុសេនាតូច ។

រ៉ាស៊ី ៖ នៅឆ្នាំ៧២ហ្នឹងដែរ?

ផល ៖ ចាំ!

រ៉ាស៊ី ៖ ជាប្រធាន?

ផល ៖ អឺ!បញ្ជា មិនមែនប្រធានទេ បញ្ជាការកងអនុសេនាតូច ។

រ៉ាស៊ី ៖ អនុសេនាតូចលេខប៉ុន្មាន?

ផល ៖ លេខ១ ។

រ៉ាស៊ី ៖ នៅក្នុងកងវរៈ អឺ!នៅក្នុងអនុសេនាធំ?

ផល ៖ អនុសេនាធំ២១ ។

រ៉ាស៊ី ៖ អនុសេនាធំ២១នឹងដែរ?

ផល ៖ ចាំ!

រ៉ាស៊ី ៖ ចឹងគ្រាន់តែដល់ភ្លាមគេឲ្យអ៊ំនៅបញ្ជាការនឹងម៉ង?

ផល ៖ ចាំ! រៀបចំឡើងគេចាត់តាំងជាបញ្ជាការ ។

រ៉ាស៊ី ៖ នៅក្នុងអនុសេនាតូចលេខ១នឹង មានគ្នាប៉ុន្មាននាក់ មានដូចជាកូនទាហាន?

ផល ៖ កូនទាហានមួយក្រុមវាមាន១២នាក់ ហើយក្នុង១២នាក់ហ្នឹង វាមាននិរសា មានសេដ្ឋកិច្ច មានពេទ្យ ។

រ៉ាស៊ី ៖ ១២នាក់នឹងមាន៣ហ្នឹងម៉ង?

ផល ៖ អានឹងថែមទេ អានិរសា សេដ្ឋកិច្ច អូ!ទាំងអស់គ្នាសរុបរួម១២នាក់ ។

រ៉ាស៊ី ៖ ចឹងធ្វើការទាំងអស់គ្នា គ្រាន់តែមានភារធំជាងតិច?

ផល ៖ ចាំ! នឹងម៉ាក្រុមវាមាន១២នាក់ ម៉ាកងហាវាមាន ។

រ៉ាស៊ី ៖ កងហា មាន៥០នាក់?

ផល ៖ ៣០ ៗជាង ។

រ៉ាស៊ី ៖ ចុះកងអនុសេនាធំមានប៉ុន្មាន?

ផល ៖ កងអនុសេនាធំវា៣កងអនុសេនាតូច ។

រ៉ាស៊ី ៖ អូ!បាទ សុំទោស ម៉ាកងអនុសេនាតូចមានប៉ុន្មាននាក់?

ផល ៖ វា៣០ ៗជាង ប៉ុនវាមិនចាំបានប៉ុន្មាន ៣០ជាងហើយ ចូលទៅ៤០អីហើយ ត្រង់បញ្ជាការ ត្រង់ស្នងការ ត្រង់អនុបញ្ជានឹង វាចូល៤០នាក់ហើយ ជាង ។

ភ៉ាស៊ី ៖ ចឹងនៅក្នុងកងអនុសេនាតូចលេខ១នឹងមានអ៊ំ ជាអ្នកបញ្ជាការ ចុះអនុបញ្ជាការឈ្មោះអី ទៅ?

ផល ៖ អនុបញ្ជាការនោះឈ្មោះ នួន ប៉ុនស្លាប់អស់ហើយ ។ ហើយក៏នៅ បែកគ្នាទៅអស់ ។

ភ៉ាស៊ី ៖ នន?

ផល ៖ ចា៎! ឈ្មោះ នួន ៗ ហើយស្នងការនោះឈ្មោះ អ៊ំ គ្រឹង ៗ ក៏ស្លាប់ដែរ ។

ភ៉ាស៊ី ៖ គ្រឹង?

ផល ៖ ចា៎!

ភ៉ាស៊ី ៖ ស្រីទាំងអស់ ឬក៏មានប្រុសដែរ?

ផល ៖ ចា៎! គ្មានប្រុសទេ កងនឹង ។

ភ៉ាស៊ី ៖ កងរបស់អ៊ំស្រីទាំងអស់?

ផល ៖ ចា៎! សុទ្ធតែស្រីទាំង ។

ភ៉ាស៊ី ៖ ចឹងអ៊ំធ្វើការតែនេះទៅសុទ្ធតែធ្វើការជាមួយស្រីរហូត?

ផល ៖ ចា៎!

ភ៉ាស៊ី ៖ ចឹងមានសមាជិក៤០នាក់?

ផល ៖ ចា៎! ដល់ហើយទៅ ខ្ញុំឡើងបានស្នងការកងអនុសេនាធំនឹងដែរ ។

ភ៉ាស៊ី ៖ នៅខែណាដែរ?

ផល ៖ មិនដឹងខែណាទេ មុន ៗ

ភ៉ាស៊ី ៖ ធ្វើបានប៉ុន្មានខែ នៅក្នុង៧/៣នឹងហើយ ឬក៏ចូល៧/៣?

ផល ៖ ៧/៣ហើយ ៗ ។

ភ៉ាស៊ី ៖ ស្នងការអនុសេនាធំលេខប៉ុន្មានដែរ?

ផល ៖ លេខ២១ ។

ភ៉ាស៊ី ៖ ចឹងដូចជាគ្រឹង ដូចជានួន អីមានដែល?

ផល ៖ ស្លាប់ ៗ ។

ភ៉ាស៊ី ៖ ស្លាប់ធ្វើសង្គ្រាន?

ផល ៖ ចា៎! ស្លាប់ទៅគេស្លាប់ ៗ ទៅ បានខ្ញុំចេះតែឡើង ៗ ។

ភ៉ាស៊ី ៖ ដល់ពេលហ្នឹង មានប៉ុន្មានកងអនុសេនាតូច?

ផល ៖ ៣ ។

រ៉ាស៊ី ៖ ពាក់កងអនុសេនាតូច?

ផល ៖ ចាស៎!

រ៉ាស៊ី ៖ ចឹងមានគ្នាប្រហែល២០០នាក់?

ផល ៖ ១០០ជាង ប្រហែលជា១២០អីនឹង ម៉ាកងអនុសេនាធំ ។

រ៉ាស៊ី ៖ ហើយទីតាំងនៅដដែល ឬក៏ដូរ?

ផល ៖ ដូរៗ អត់នៅដដែលទេ គ្រាន់តែថាវាជុំវិញ ។

រ៉ាស៊ី ៖ ជុំវិញក្រុង ខ្សែក្រវាត់ក្រុងអីចឹង?

ផល ៖ ចាស៎! ជួនកាលទៅពីខាងជើងចឹងទៅ ជួនកាលទៅពីខាងកើតចឹងទៅ ណាខ្លះទៅពីត្បូងចឹងទៅ ស្រេចតែគេបញ្ជាពីលើតំរូវនោះ ។

រ៉ាស៊ី ៖ អ៊ំអត់មានដឹងថានៅក្នុងកងពលអីទេ?

ផល ៖ អត់ដឹង ដឹងតែថាតំបន់១៣ ។

រ៉ាស៊ី ៖ តំបន់១៣ នៅក្នុងភូមិភាគនិរតី?

ផល ៖ ចាស៎!

រ៉ាស៊ី ៖ ចុះអ៊ំមានដឹងអំពីកងពលពិសេសៗហ្នឹងគឺ កងពល៧០៣ កងពលនឹងវៃចូលទីក្រុងភ្នំពេញមុនគេបំផុត?

ផល ៖ ក្រៅពីក្នុងតំបន់១៣ហ្នឹង ខ្ញុំអត់ដឹង ។

រ៉ាស៊ី ៖ ពីការងារធ្វើអីខ្លះ?

ផល ៖ មានធ្វើអី គ្មានធ្វើអីទេ នៅតែរឿងគិតគូររឿងទ័ពនឹង ។

រ៉ាស៊ី ៖ គេមាន ដូចថាខាងកងពល ខាងតំបន់អីគេបំពាក់អាវុធអីឲ្យគ្រប់គ្នា?

ផល ៖ ចាស៎! មានគ្រប់គ្នា ចូលសមរភូមិដែរ ។

រ៉ាស៊ី ៖ ចូលសមរភូមិដែរ?

ផល ៖ ចាស៎!

រ៉ាស៊ី ៖ ទៅប្រយុទ្ធជាមួយគេ ឬក៏យើងទៅរបៀបជាអ្នកសែងរបួស?

ផល ៖ ទៅប្រយុទ្ធម៉ង ចូលដូចថាកងយុវជនគេចូល យើងក៏ទៅដែរជាមួយគេ ។

រ៉ាស៊ី ៖ យើងទៅទីក្រុង?

ផល ៖ ចាស៎! បើគេត្រៀម យើងដឹកគ្រាប់សេរ ត្រៀមដូចគ្នា ។

រ៉ាស៊ី ៖ ហើយកាំភ្លើងដែលគេចែកឲ្យហ្នឹង កាំភ្លើងម៉ាកអីទៅ?

ផល ៈ មានអាកា កាប៊ីន ក្បាលម៉ាជីន ។

រ៉ាស៊ី ៈ ក្បាលម៉ាជីនហ្នឹងម៉េចទៅ?

ផល ៈ ក្បាលម៉ាជីនអាគេកាច់ ។

រ៉ាស៊ី ៈ ខ្ញុំអត់សូវស្គាល់ទេ ប្រភេទកាំភ្លើង ។

ផល ៈ អាសុរ៉ាន់ឌីណែនឹង ។

រ៉ាស៊ី ៈ អានឹងគេហៅអីគេ?

ផល ៈ ក្បាលម៉ាជីន អានឹងពាក្យយួន ។

រ៉ាស៊ី ៈ ហើយកាំភ្លើងនឹងមកពីខាងណា ៗ គេអ្នកជំនួយឲ្យមក?

ផល ៈ ពីខាង ៗ ខ្ញុំក៏មិនដឹងដែរ ប៉ុនគ្រាន់ថាថ្នាក់លើគេណែនាំយកមក ។

រ៉ាស៊ី ៈ គេយកមកបើកឲ្យ?

ផល ៈ ចា៎!

រ៉ាស៊ី ៈ ហើយអីជាស្នងការ ជាបញ្ជាការចឹង មានកាំភ្លើងខ្លីកាន់?

ផល ៈ អត់មាន ។

រ៉ាស៊ី ៈ ក្រោយមកអីធ្វើនៅនឹងបានប៉ុន្មានខែ ប៉ុន្មានឆ្នាំ?

ផល ៈ ដល់ពេលឆ្នាំ៧៤ ខ្ញុំត្រូវរបួស ។

រ៉ាស៊ី ៈ ត្រូវរបួសត្រង់ណាដែរ អីុ?

ផល ៈ ជើង មុនដំបូងត្រូវដៃ ៗ ត្រូវតិចតួចទេ ដល់ជើងពីក្រោមកកំបាក់ត្រង់សេម៉ង ។

រ៉ាស៊ី ៈ អាហ្នឹងនៅសមរភូមិណា?

ផល ៈ នៅតាកែវ ។

រ៉ាស៊ី ៈ សមរភូមិតាកែវ?

ផល ៈ ចា៎!

រ៉ាស៊ី ៈ ហ្នឹពេលនឹងប្រយុទ្ធគ្នាជាមួយកងទ័ពលន់ នល់ ឬក៏កងទ័ពយួន?

ផល ៈ កងទ័ពលន់ នល់ ។

រ៉ាស៊ី ៈ ពេលដែលអីត្រូវរបួសហ្នឹង ខាងអីប្រយុទ្ធឈ្នះ ៗ គេទេ?

ផល ៈ មិនទាន់ឈ្នះទេ នៅគ្រាន់ថាទាហានវ៉ាចេញប្រតិបត្តិការណ៍បុកទម្លាយត្រង់សេយើង ដែល
ថ្លោងកំបាក់ត្រង់សេរ ហើយវ៉ាចូលមក ។

រ៉ាស៊ី ៈ គេអត់ចាប់អី គ្មាអី?

ផល ៖ វារកអត់ទាន់ឃើញ ។

រ៉ាស៊ី ៖ វារកអត់ឃើញ អ៊ំនៅពួន?

ផល ៖ ខ្ញុំនៅត្រង់សេរហ្នឹង ព្រោះវាខ្ញុំបាក់ជើង អត់លូនរួចទេ ។

រ៉ាស៊ី ៖ ត្រូវជើងណាអ៊ំ ជើងស្តាំ ហើយឆ្វេង?

ផល ៖ ត្រូវជើងខាងស្តាំ បាក់ខាងស្តាំ ។

រ៉ាស៊ី ៖ ចុះឥឡូវនេះអត់អីទេ?

ផល ៖ ឥឡូវវាដើរ វាតអត់ត្រង់ ព្រោះអីពេលគំរប់៧ថ្ងៃវាត្រូវឆ្អឹងត ឡានហោះទម្លាក់គេសែង ខ្ញុំរត់ទៀត ដូចថាឆ្អឹងតវារលាក់ៗ វាជិះ ។

រ៉ាស៊ី ៖ ចុះឡានហោះទម្លាក់នឹងតាំងពីឆ្នាំណាមក?

ផល ៖ ៧៤ ។

រ៉ាស៊ី ៖ នៅឃើងនោះមានទម្លាក់ខ្វះ?

ផល ៖ ទម្លាក់ ។

រ៉ាស៊ី ៖ ទម្លាក់ម៉ុំណាខ្វះ?

ផល ៖ ទម្លាក់ភ្នំខាងត្បូងនឹងក៏ទម្លាក់ ឡានទម្លាក់គ្រប់កន្លែង កាលនៅសមរភូមិនោះក៏ទម្លាក់៧៤ យកទៅយកនៅមន្ទីរពេទ្យនោះទៅ ដល់ពេលខ្ញុំជាទៅគេឲ្យមកនៅក្រោយវិញ គេលែងឲ្យទៅមុខទៀត ។

រ៉ាស៊ី ៖ មកនៅក្រោយនេះ អ៊ំមកនៅណាវិញ?

ផល ៖ មកឃុំកំពែង ។

រ៉ាស៊ី ៖ នឹងពី៧៤មក?

ផល ៖ ៧៤ ។

រ៉ាស៊ី ៖ ខែណាទៅអ៊ំ?

ផល ៖ អត់ចាំ ខែ៨ ខែ៩ដឹង បើដេកពេទ្យ ចេញមកគេឲ្យមកនៅ ។

រ៉ាស៊ី ៖ នៅជាកងទ័ពដដែល ឬលែងជាកងទ័ព?

ផល ៖ លែងកងទ័ព ចេញពីអង្គភាពទ័ព គេឲ្យមកនៅឃុំកំពែងនឹង ជាសមាជិកឃុំ សមាជិកគណៈអចិន្ត្រៃយ៍ឃុំ ។

រ៉ាស៊ី ៖ នៅនេះមានសមាជិកគណៈអចិន្ត្រៃយ៍ឃុំប៉ុន្មាននាក់ដែរ នៅក្នុងឃុំកំពែងអ៊ំធ្វើនឹង?

ផល ៖ នៅក្នុងសមាជិកគណៈអចិន្ត្រៃយ៍ ក្នុងឃុំហ្នឹងវាមាន៣នាក់ ហើយផ្នែកខាងបុរសអីចឹង គេមានផ្នែកច្រើនគេ ។

រ៉ាស៊ី ៖ បាទ! ឥឡូវនេះខ្ញុំចង់សួរខ្ញុំចង់ដឹងអំលំអិតដែរ កាលហ្នឹងគេហៅគណៈឃុំឈ្មោះអីដែរ?

ផល ៖ ឈ្មោះ តាញ៉ែប ហ្នឹង ។

រ៉ាស៊ី ៖ ញ៉ែប គាត់ជាគណៈឃុំ?

ផល ៖ ចា៎! ប្រធាន ។

រ៉ាស៊ី ៖ ចឹងគណៈឃុំហ្នឹង គាត់គ្រប់គ្រងទៅលើអីខ្លះ?

ផល ៖ គ្រប់គ្រងទូទៅទាំងអស់មួយឃុំហ្នឹង ។

រ៉ាស៊ី ៖ ចឹងនៅក្នុងមួយឃុំហ្នឹង មានគណៈកម្មការអចិន្ត្រៃយ៍ហ្នឹងប៉ុន្មាននាក់?

ផល ៖ ក្នុងគណៈកម្មការមាន៣ ។

រ៉ាស៊ី ៖ គណៈកម្មការមាន៣នាក់ មានឈ្មោះអីខ្លះ?

ផល ៖ ឈ្មោះ តាញ៉ែប ហ្នឹង ហើយឈ្មោះ តាសារូ នេះនៅកើតនេះដែរ ហើយនិងខ្ញុំហ្នឹងឯង ៣នាក់នឹង ក្រៅពីនឹង ។

រ៉ាស៊ី ៖ ចឹងញ៉ែបជាប្រធាន ចុះសារូនេះ?

ផល ៖ ជាអនុ ។

រ៉ាស៊ី ៖ ហើយអ៊ំជា?

ផល ៖ សមាជិក ។

រ៉ាស៊ី ៖ ចឹងខ្ញុំចង់ដឹងថា ឥឡូវអនុនោះ តួនាទីរបស់គាត់គ្រប់គ្រងអីខ្លះ?

ផល ៖ គាត់ខាងផ្នែកខាងយោធា ។

រ៉ាស៊ី ៖ ហើយអីទៀត?

ផល ៖ ផ្នែកខាងយោធានឹង ហើយ ។

រ៉ាស៊ី ៖ ចុះសេដ្ឋកិច្ចអី?

ផល ៖ សេដកិច្ចនឹងវាមានដូចថាសេដកិច្ច សន្តមកិច្ច និយាយរួមគេក្តាប់ទាំងអស់ ប៉ុនវាមានចែកមុខគ្នា ។

រ៉ាស៊ី ៖ ចែកមុខគ្នាគ្រប់គ្រង?

ផល ៖ ចា៎! ប៉ុនជាធម្មតាគ្រប់គ្រងទាំងអស់គ្នា សរុបគ្នា គ្រាន់ថាអានេះទៅអានេះ ។

រ៉ាស៊ី ៖ ហើយអ៊ំគេឲ្យកាន់ខាងអីទៅ?

ផល ៖ ខ្ញុំក៏ដើរមិនទាន់រឹងប៉ុងកាលនឹងទៅ ។

រ៉ាស៊ី ៖ នៅឈឺនៅឡើយ?

ផល ៖ ចា៎! ធ្វើតាមគេចឹងទៅគេហៅទៅប្រជុំណា ទៅរួចទៅៗ ទៅមិនរួចខ្ញុំនៅ ។

រ៉ាស៊ី ៖ គេឲ្យកាន់ខាងផ្នែកអីដែរអ៊ំ ព្រោះមានផ្នែកច្រើនណាស់នៅក្នុងឃុំ?

ផល ៖ កាន់ខាងពេទ្យ ខាងនារី ។

រ៉ាស៊ី ៖ ចុះផ្នែកសេដ្ឋកិច្ចនៅលើញ៉ែបនេះ ជាអ្នកមើល?

ផល ៖ ចា៎! ញ៉ែប អ្នកមើល ។

រ៉ាស៊ី ៖ ចឹងញ៉ែបនេះមកនេះ តាំងពីឆ្នាំ៧៤មក ឬក៏មុន?

ផល ៖ មកៗឆ្នាំ៧៤នឹង ព្រោះអីខ្ញុំមកដល់ឃើញគាត់នៅហ្នឹងហើយ ៧៤ ហើយក៏មកពី៧៣ក៏មិនដឹង ។

រ៉ាស៊ី ៖ ចឹងនៅកំពែងគេរៀបចំដូចថាការគ្រប់គ្រងតាមរបៀបខ្មែរក្រហមរួចទៅហើយ ឆ្នាំ៧៤?

ផល ៖ ចា៎!

រ៉ាស៊ី ៖ ព្រោះពីមុនមក ភូមិនេះ អត់ទាន់មានការគ្រប់គ្រងច្បាស់លាស់ ពី៧១ ៧២មក ដោយសារនៅជាតំបន់ប្រទាញ ប្រទុង ។

ផល ៖ ចា៎! តំបន់ខ្វះឃឹត ។

រ៉ាស៊ី ៖ ចឹងកាលហ្នឹងមានការបង្កើតចេញជាសហករណ៍ហើយឬនៅ ៧៤?

ផល ៖ ៧៥បានកើតជាសហករណ៍ ៧៤វាមានៗតិចតួច ទើបរៀបកសាងតិចតួច មិនទាន់លះបង់បាន ដល់៧៥ក្រោយពីរំដោះភ្នំពេញមក បង្កើតសហរកណ៍ ។

រ៉ាស៊ី ៖ ហើយអ៊ំនៅធ្វើនឹងរហូតដល់ឆ្នាំណាបានចប់ ទាល់តែឆ្នាំចប់ម៉ង?

ផល ៖ ដល់៧៤ ៧៥ខ្ញុំនៅនឹង ដល់ហើយគេឲ្យខ្ញុំនៅឆ្នាំប៉ុន្មានគេឲ្យទៅខាងព្រៃអំពក រៀបរត់ហើយ ។

រ៉ាស៊ី ៖ ជិតរត់ហើយ?

ផល ៖ ចា៎!

រ៉ាស៊ី ៖ អាចថាឆ្នាំ៧៨?

ផល ៖ ៧៧នៅកំពែងនឹងដដែល ។

រ៉ាស៊ី ៖ ចឹងកាលនោះខ្ញុំចង់ដឹងថានៅឃុំកំពែងនឹង ឥឡូវខ្ញុំនិយាយពី៧៥មក ពេលដែលប៉ុលពតគាត់គ្រប់គ្រងបានប្រទេសទាំងមូលហើយ ស្រុកទេសយើងបានឯករាជ្យហើយ ចឹងគេ

រៀបចំរចនាសម្ព័ន្ធនៅក្នុងឃុំយ៉ាងដូចម្ដេចដែរ នៅក្នុងឃុំកំពែងនឹង?

ផល : គេរៀបជាក្រុមៗគេនឹង ។

វ៉ាស៊ី : មានពួកទេ?

ផល : ពួកមាន ។

វ៉ាស៊ី : ក្រុមតូចជាងពួក ឬពួកតូចជាងក្រុម?

ផល : ពួកតូចជាងក្រុម ។

វ៉ាស៊ី : ក្រុម?

ផល : ក្រុមតូចជាងកង ។

វ៉ាស៊ី : កងតូចជាង?

ផល : តែកងៗ ។

វ៉ាស៊ី : វ៉ានៅក្នុងសហករណ៍តែមួយ?

ផល : ចា៎! កងៗដូចថាក្នុងម៉ាឃុំចឹង គេសរុបចូលថាអានឹងគេរៀបចំដូចក្នុងម៉ាឃុំគេប្រុងធ្វើប៉ុន្មានកងចឹង គេប្រមូលដូចថា២ភូមិ ឬក៏៣ភូមិគេធ្វើម៉ាកងតូច ស្រេចលើកភូមិតិចភូមិច្រើន ។

វ៉ាស៊ី : បើភូមិច្រើនចឹង តាមម៉ាភូមិចឹងទៅ?

ផល : ចា៎!

វ៉ាស៊ី : ចុះសហករណ៍មានមិនមែនម៉ាភូមិទេ ច្រើនភូមិ ឬក៏?

ផល : ចា៎! ២ភូមិអីចឹងទៅ ។

វ៉ាស៊ី : ហើយនៅក្នុងឃុំកំពែងនឹងមានប៉ុន្មានសហករណ៍ អឺ!មានប៉ុន្មានកងដែរម៉ាសហករណ៍?

ផល : ភ្លេចអស់ហើយ យូរពេកភ្លេចអស់ ដឹងប៉ុន្មានកងៗ ។

វ៉ាស៊ី : ឃុំកំពែងនេះ តែម៉ាសហករណ៍ទេ ឬក៏មានបញ្ជូនពី?

ផល : ច្រើនៗសហករណ៍ដែរ ប៉ុនខ្ញុំ ។

វ៉ាស៊ី : មានសហករណ៍ប៉ុន្មានទៅ ហើយអ្នកណាគេគ្រប់គ្រងខ្លះ?

ផល : ភ្លេចអស់ ខ្ញុំភ្លេចអស់ហើយ ។

វ៉ាស៊ី : រកនឹកតិច?

ផល : ភ្លេចទាំងអស់គ្រប់គ្រងនៅនឹងអស់ ។

វ៉ាស៊ី : មានប៉ុន្មានសហករណ៍? សហករណ៍អីខ្លះទៅ?

ផល ៖ ខ្ញុំរកនឹកមើល នៅម៉ាភូមិវាភ្លេចអស់ទៅ យូរពេក នៅមិនបានចាប់អារម្មណ៍រឿងចង់ចាំនឹង ។ ច្រកដីកុំ ភូមិធំ ហើយអាងខ្មៅ កំពែង ប្រាសាទពោធិ៍បាយ អន្លុញ ស្វាយវាល់ តាម៉េងនេះ ច្រើនណាស់ សហករណ៍ ហាន់ទា ដីម្រះអីច្រើនណាស់សហករណ៍គេ ។

វ៉ាស៊ី ៖ ចឹងកាលជំនាន់នោះ អត់ហៅភូមិទេ ហៅសហករណ៍វិញ?

ផល ៖ គេហៅភូមិដែរ ។

វ៉ាស៊ី ៖ ចឹងក្នុងសហករណ៍មួយនឹងមានមួយភូមិ ឬក៏?

ផល ៖ ជួនកាលគេភូមិណាប្រជាជនតិចទៅ គេសរុបចូលគ្នា ។

វ៉ាស៊ី ៖ ចឹងកំពែងនេះ ឃុំធំណាស់?

ផល ៖ ធំ ។

វ៉ាស៊ី ៖ ហើយក្នុងសហករណ៍មួយៗនឹង មានដូចថារចនាសម្ព័ន្ធគ្រប់គ្រង ការគ្រប់គ្រងគេបែងចែកយ៉ាងម៉េច មានប្រធានសហករណ៍?

ផល ៖ មានប្រធានសហករណ៍គេ មានប្រធានក្រុម ។

វ៉ាស៊ី ៖ មានប្រធានក្រុម អត់មានជាកងអីទេនោះ?

ផល ៖ កងពួកកងៗដល់ចេញទៅជីកប្រឡាយជីកអីអានឹងគេចាត់ជាកង នៅក្នុងនឹង ។

វ៉ាស៊ី ៖ ហើយមុខព្រួញធ្វើការសហករណ៍មួយៗ ធ្វើការមុខព្រួញដូចៗគ្នា ឬក៏?

ផល ៖ ធ្វើដូចគ្នា តែគេឲ្យទៅរែកដីទៅរែកចឹងទៅ គេរើសតាមភូមិប៉ុណ្ណេះៗប៉ុន្មានចឹងទៅ ។

វ៉ាស៊ី ៖ ហើយចុះពេលប្រជុំដាក់ផែនការម្ដងៗ ខាងឃុំហៅទាំងប្រជាជន ទាំងប្រធានមកប្រជុំទាំងអស់គ្នា ឬក៏យ៉ាងម៉េច?

ផល ៖ គេហៅ ជួនកាលគេហៅតែប្រធានៗ ជួនកាលគេហៅប្រជុំត្រឹមប្រជាជន ។

វ៉ាស៊ី ៖ ពេលប្រជុំហ្នឹង តើគេដាក់ផែនការអីខ្លះជាទូទៅ?

ផល ៖ ដូចជាផែនការតាមមុខសញ្ញាដូចជាធ្វើដី ដាំដំណាំ រែកដី ជីកប្រឡាយអីចឹងទៅ ហើយក៏ត្រូវការជ្រើសរើសទៅធ្វើស្រែប្រាំងអី គេរើសតាមកម្លាំងអីចឹង ។

វ៉ាស៊ី ៖ ចុះក្នុងនឹងដូចថាមានបែងចែកជាកងនារី កងយុវជនអីទេ?

ផល ៖ មាន ។

វ៉ាស៊ី ៖ ហើយអ៊ំនេះគ្រប់គ្រងកងនារីសុទ្ធ?

ផល ៖ ផ្នែកខាងនារីគេ មានអ្នកគ្រប់គ្រង ។

វ៉ាស៊ី ៖ ប៉ុន្តែនៅក្រោម តាញ៉ែប ក្រោមអ៊ំ ហើយក្រោមតាសារូ?

ផល ៖ វាមានប្រធានយុវជន មានប្រធានយុវនារី មានប្រធាននារីកសិករ ។

វ៉ាស៊ី ៖ មានប្រធាននារីកសិករទៀត?

ផល ៖ ចាំ!

វ៉ាស៊ី ៖ ប្រធាននឹងយ៉ាងម៉េចទៅ នារីកសិករយ៉ាងម៉េចទៅ?

ផល ៖ មានគ្រួសារហើយ ។

វ៉ាស៊ី ៖ អ្នកមានគ្រួសារហើយគេថានារីកសិករ?

ផល ៖ ចាំ!

វ៉ាស៊ី ៖ ចុះនារីនៅលីវ?

ផល ៖ យុវនារី ។

វ៉ាស៊ី ៖ ចុះកងចល័ត គេឲ្យនារីដែរនៅលីវ?

ផល ៖ យុវនារីកងចល័តនឹង ជួនកាលទៅតែយុវនារីកងចល័តនឹង ។ ជួនកាលកងមេម៉ាយៗក៏ទៅចល័តដែរ ម៉េម៉ាយអត់មានកូនពួជ ។

វ៉ាស៊ី ៖ អ្នកមានគ្រួសារនៅក្នុងកងកសិករ?

ផល ៖ ចាំ! ជួនកាលអ្នកមានគ្រួសារ តែអត់កូនខ្ចី គេឲ្យទៅកងចល័តដែរនឹង ។

វ៉ាស៊ី ៖ ចុះកងចល័តថាមានត្រឹមកងចល័តឃុំ ឬក៏មានកងចល័តស្រុកដែរ?

ផល ៖ កងចល័តតែឃុំ រៀបចំពីឃុំនេះទៅ ។ ដល់ទៅដល់គេត្រូវការស្រុកយកប៉ុន្មាន គេរើសពីតាមឃុំទៅ ។

វ៉ាស៊ី ៖ ចុះឧទាហរណ៍ថា ឥឡូវផែនការដែលដាក់ចុះទៅ ស្រាប់តែខាងកងឬក៏ក្រុមសហករណ៍នីមួយៗធ្វើអត់បានតាមផែនការរបស់ឃុំ តើគិតយ៉ាងម៉េចដែរ?

ផល ៖ អាហ្នឹងគេអ្នកតាមទៅ ខ្ញុំក៏មិនដឹងដែរ ខ្ញុំនៅខាងក្រោយនេះ គេអ្នកទៅប្រឡូកផ្ទាល់ ផែនការគេដឹកប្រឡាយដឹកចឹងទៅ ខ្ញុំអត់បាន ។

វ៉ាស៊ី ៖ ចឹងអ៊ំអត់ចុះទៅជាមួយទេ?

ផល ៖ ចាំ!

វ៉ាស៊ី ៖ អ៊ំនៅធ្វើរដ្ឋបាលនៅក្នុងឃុំ?

ផល ៖ នៅក្នុងឃុំ ព្រោះខ្ញុំដើរមិនសូវរួចដែរ ។

វ៉ាស៊ី ៖ ចឹងចង់ដឹងថា ការងារដែលអ៊ំធ្វើនៅក្នុងមន្ទីរឃុំនឹងធ្វើការអីខ្លះទៅ?

ផល ៖ ដើរមើលខាងក្រោយ នៅកន្លែងពេទ្យ កន្លែងដាំដំណាំ កន្លែងដាំបាយដាំអីក្រោយៗនឹង ។

រ៉ាស៊ី ៖ ចុះមានផ្ញើបញ្ញើស្នាម ឬក្រដាសអី ដូចថាមានសារ មានអីផ្ញើពីសហករណ៍លិខិតស្នាម សំបុត្រពីស្រុកអីមកដែរទេ?

ផល ៖ មានតើ ។

រ៉ាស៊ី ៖ មានសំបុត្រគេផ្ញើពីខាងស្រុក កាលនឹងគេហៅស្រុក?

ផល ៖ ស្រុក ។

រ៉ាស៊ី ៖ កាលនោះអ្នកណាគេគណៈស្រុក?

ផល ៖ គណៈស្រុកកាលនោះ តាគុំ ។

រ៉ាស៊ី ៖ ចុះយាយបូ?

ផល ៖ យាយបូក៏ជាគណៈស្រុកដែរ តាគុំ យាយបូ ។

រ៉ាស៊ី ៖ គុំហ្នឹងមកពីខាងណា?

ផល ៖ ត្រាំកក ។

រ៉ាស៊ី ៖ យាយបូ?

ផល ៖ យាយបូក៏ត្រាំកក់ ហើយតាទិតដែរ ។ តាទិតនឹង នៅស្រុកណាដង តាទិតនឹងនៅស្រុកណា តាទិតនៅត្រាំកក់ដែរអី មិនស្គាល់ ដឹងស្គាល់តែតាទិត ។

រ៉ាស៊ី ៖ តាទិតនឹង គាត់ជាគណៈស្រុកដែរ?

ផល ៖ ចា៎! គណៈជាមួយ៣នាក់នឹង តាគុំ តាទិត យាយបូនឹង ។

រ៉ាស៊ី ៖ ណាធំជាងគេ ៣នាក់នឹង?

ផល ៖ តាគុំ ។

រ៉ាស៊ី ៖ តាគុំធំជាងគេ?

ផល ៖ ចា៎!

រ៉ាស៊ី ៖ ចុះយាយបូ?

ផល ៖ យាយបូនោះ បន្ទាប់មក ។

រ៉ាស៊ី ៖ តាទិត?

ផល ៖ តាទិតនោះ អនុគេហើយ ។

រ៉ាស៊ី ៖ តាទិតរៀងតូចជាងគេ?

ផល ៖ ចា៎!

រ៉ាស៊ី ៖ ទាំង៣នាក់នឹង មានបន្ទុកខុសៗគ្នា?

ផល :	ចា៎!

រ៉ាស៊ី :	គាត់នេះ ដឹងតែក្តាប់រួមហើយ គាត់ជាគណៈស្រុក?

ផល :	ចា៎!

រ៉ាស៊ី :	ចុះយាយបូនេះ គាត់ក្តាប់ខាងអីដែរ?

ផល :	យាយបូនេះ គាត់ដើរសព្វផ្សាយខាងនារី គាត់ក្តាប់រួមទាំងអស់ បុរស-នារី យុវជនស្ត្រី គាត់ក្តាប់ទាំងអស់ដែរ ។

រ៉ាស៊ី :	តាទិតហ្នឹង កាលនោះគាត់អាយុប្រហែលជាប៉ុន្មាន?

ផល :	ចាស់ច្រើនដែរ ៥០-៦០ជាងហើយ ។

រ៉ាស៊ី :	ចុះឥឡូវបើនៅ៩០បាត់ហើយ?

ផល :	ចា៎!

រ៉ាស៊ី :	គាត់នៅរស់ ហើយអត់ទេ?

ផល :	តាទិតនោះ ថានៅទល់ដែនថៃ ឥឡូវដឹងស្លាប់ហើយនៅ ។

រ៉ាស៊ី :	ដឹងថានៅក្នុងស្រុកអី ខេត្តអី?

ផល :	សែនចៅ នៅទល់ដែនថៃ ។

រ៉ាស៊ី :	នៅក្នុងខេត្តបន្ទាយមានជ័យតាមមើល?

ផល :	ដឹងខេត្តណា ខ្ញុំដឹងខាងសែនចៅ ។

រ៉ាស៊ី :	ចុះយាយបូៗ?

ផល :	យាយបូនោះ រត់ទៅ អត់ដឹងតាំងពីរត់បែក ខ្ញុំអត់ដឹង ប៉ុន្តែគ្រាន់ដឹងថាតាទិតនឹងដឹងទៅនៅទល់ដែនថៃ ។

រ៉ាស៊ី :	ក្រោយមកមានដំណឹងពីគាត់ទៀតទេ?

ផល :	អត់ៗដឹង ។

រ៉ាស៊ី :	គាត់តួនាទីគាត់ទទួលបន្ទុកអីខ្លះដែរ ជាអនុគណៈស្រុកកាលពីជំនាន់នោះ តួនាទីគាត់គ្រប់គ្រង គាត់ទទួលបន្ទុកលើអីខ្លះ?

ផល :	ទាំងអស់គ្នា ទាំង៣នាក់នឹង ធ្វើការដូចៗគ្នា ទៅណាទៅគ្នាទៅ ។

រ៉ាស៊ី :	ប៉ុន្តែជាទូទៅដូចថាមាន៣នាក់ចឹង មេដឹងថាគ្រប់គ្រងទាំងអស់ ហើយសំខាន់មានសេដ្ឋកិច្ច យោធា ហើយនឹងនយោបាយ ។ ចឹងនៅក្នុងនឹងដូចខ្ញុំជម្រាបអីចឹង មានសេដ្ឋកិច្ច មាន យោធា ហើយនឹងនយោបាយ បើអាចថាអនុប្រធានមួយគ្រប់គ្រងសេដ្ឋកិច្ច អនុប្រធាន

មួយគ្រប់គ្រងនយោបាយ អនុប្រធានមួយគ្រប់គ្រងខាងយោធាចឹង ។ ចឹង៣នាក់នឹង ការទទួលខុសត្រូវខុសៗគ្នា ទាំង៤ ទទួលខាងនារីខាងអី ។

ផល : ប៉ុនគាត់ក្តាប់ជារួម ម៉ាថ្នាក់ៗ លើ ខ្ញុំមិនសូវដឹងគ្រប់គ្រងតាមអីឲ្យម៉ត់ចត់ខ្ញុំអត់ដឹង ។

វ៉ាស៊ី : តែអ៊ីដែលឡើងទៅជួបជាមួយគាត់នៅនោះ?

ផល : ចា៎! ប្រជុំ ខ្ញុំមិនសូវដឹងដែរទេ!

វ៉ាស៊ី : ប៉ុន្តែអ៊ីដែលទៅប្រជុំជាមួយគាត់ដែរទេ?

ផល : ទៅ! មួយខែទៅម្តង ដួនកាលមានប្រជុំកន្លះខែទៅ ស្ថានភាព ។

វ៉ាស៊ី : ចុះគុំនេះនៅរស់ទេ?

ផល : ប្រហែលជាស្លាប់បាត់ហើយ ខ្ញុំមិនដែលឮដំណឹង ស្លាប់ហើយបែបក្រោយមកគេថាគាត់គុំ នឹងក្បត់ ។

វ៉ាស៊ី : គេចាប់នៅក្នុងជំនាន់នឹងដែរ?

ផល : កាលម៉ាជំនាន់នឹង ដល់ពេល ដល់គេថាគាត់គុំនឹងក្បត់ ពួកខ្ញុំក៏ធាក់ថយដែរ ដល់ពេលដក សេចក្តីទុកចិត្ត កាលមេដឹកនាំយើងថាក្បត់ហើយ កូនចៅក៏ គេដកសេចក្តីទុកចិត្ត ។

វ៉ាស៊ី : ចុះមីងមានស្គាល់ឈ្មោះតាអាន់ទេ?

ផល : មានតែតាខាន់ ។

វ៉ាស៊ី : តាខាន់ តាអាន់ អត់មាន?

ផល : អត់ តាអាន់នឹង ក្រែងនៅភូមិណាអត់មានដូចជាមិនដែលឮ ។

វ៉ាស៊ី : គាត់នៅក្នុងជួរគណៈកម្មការស្រុកដែរ?

ផល : តាខាន់នឹងនៅឃុំ ដូចតាអាន់នឹងដូចខ្ញុំមិនដែលឮ ។

វ៉ាស៊ី : គាត់នៅឃុំណា តាខាន់ហ្នឹង?

ផល : នៅព្រៃអំពក ។

វ៉ាស៊ី : នៅស្រុកគិរីវង់?

ផល : ចា៎! គិរីវង់ ប៉ុនដូចខាងត្បូងភ្នំ ។

វ៉ាស៊ី : ចុះមីងយ៉ន់?

ផល : ដូចគ្មានដែលឮ ។

វ៉ាស៊ី : មីងយ៉ន់ សុទ្ធនៅក្នុងជួរគណៈកម្មការអេចិន្ត្រៃយ៍ដែរ?

ផល : ដូចអត់ដែលឮយ៉ន់ ។

វ៉ាស៊ី ៖ ចុះភាន់?

ផល ៖ ភាន់ហ្នឹងនៅផ្នែកខាងយុវនារី ប្រធានយុវនារីឃុំកំពែង ។ យ៉ង់ដូចខ្ញុំមិនដែលព្ធ ។

វ៉ាស៊ី ៖ សព្វថ្ងៃហ្នឹងនៅរស់ទេ ភាន់?

ផល ៖ នៅប៉ុននៅឯណាទេ នៅកំពង់សោម គេរកស៊ី គេដើររកស៊ី ហើយខ្ញុំក៏មិនដែលបានជួប បានឃើញអីទេ ។

វ៉ាស៊ី ៖ ចុះអួន?

ផល ៖ អួនហ្នឹងៗនៅខាងរាមអណ្ដើក ។

វ៉ាស៊ី ៖ គាត់ជាអីដែរ?

ផល ៖ នារីឃុំដែរ ។

វ៉ាស៊ី ៖ ប្រធាននារីឃុំដែរ?

ផល ៖ ដូចជាមិនប្រធានទេ ដូចមិនដឹងអាណាប្រធាន អាណាអនុអី ខ្ញុំ ។

វ៉ាស៊ី ៖ ចុះបើយើងទៅសួរគេនៅខាងរាមអណ្ដើកគេដឹង?

ផល ៖ ដឹង ។

វ៉ាស៊ី ៖ គេដឹង នារីអួនៗ?

ផល ៖ អត់នៅស្រុកយើងនេះទេ នៅស្រុកណាមិនដឹង មកពីណា ។

វ៉ាស៊ី ៖ នៅរស់ដែរសព្វថ្ងៃ?

ផល ៖ អត់ដឹង ។

វ៉ាស៊ី ៖ ទៅខាងរាមអណ្ដើកមិនដឹងជាសួរអ្នកណាគេអាចដឹង?

ផល ៖ មាននៅខាងរាមអណ្ដើក មានគណៈឃុំដឹងនៅមិននៅប៉ុនថា មាននារីឃុំនៅមួយឈ្មោះវ៉ាន់ ម៉ា ។

វ៉ាស៊ី ៖ គាត់នៅរាមអណ្ដើកនឹង?

ផល ៖ ចាំ!

វ៉ាស៊ី ៖ នៅភូមិអីដែរ?

ផល ៖ នៅភូមិដូចត្រពាំងរុនមិនដឹងទេ ភូមិគេនឹង ។

វ៉ាស៊ី ៖ គាត់ជានារីឃុំដែរ?

ផល ៖ នារីឃុំ ។

វ៉ាស៊ី ៖ នាមត្រកូលគាត់ឈ្មោះអីទៅ?

ផល ៖ អត់ដឹងឈ្មោះអី ។

វ៉ាស៊ី ៖ ចាំមើលខ្ញុំទៅសួរគេ ។

ផល ៖ ប្រធានភូមិ ប្រធានឃុំអី មិនដឹងអ្នកណាជាអ្នកណា ខ្ញុំមិនដឹងទេ ។ ស្គាល់តែនារី

វ៉ាស៊ី ៖ ចឹងខ្ញុំចង់ត្រឡប់មកសួរអីវិញ ពីនៅក្នុងឆ្នាំ៧៥ ៧៦ ៧៧ ខ្ញុំចង់ដឹងការងារ របស់អ៊ំនៅជំនាន់នឹង ធ្វើអីខ្លះ ហើយអ្នកណាជាអ្នកបញ្ជាអ៊ំ ឲ្យធ្វើអីចឹង?

ផល ៖ មានធ្វើអី បើធ្វើគេឲ្យដឹកនាំធ្វើដី ទៅប្រមូលអាចម៍គោប្រមូលអី នឹងទៅជាមួយគេ ។

វ៉ាស៊ី ៖ ញ៉ៅប?

ផល ៖ ញ៉ៅបនឹង ដល់៧០ប៉ុន្មានទេ ត្រូវបែកកម្មដ្ឋានមានស្រី ។

វ៉ាស៊ី ៖ មានស្រី ខុសសីលធម៌?

ផល ៖ មានស្រី យកប្រធានភូមិ នារីភូមិអី យកពេទ្យអីនឹង បានកូនរ៉ៅញ៉ៅចឹងទៅ គេចាប់យកទៅបាត់ទៅ ។

វ៉ាស៊ី ៖ ហើយញ៉ៅបនឹងមានប្រពន្ធហើយ?

ផល ៖ ចា៎! មានប្រពន្ធហើយ ដល់មិនដឹង៧០ប៉ុន្មាន ៧៧អីនឹង ។

វ៉ាស៊ី ៖ នារីពេទ្យហ្នឹងឈ្មោះ ភាព?

ផល ៖ ភាព ។

វ៉ាស៊ី ៖ ហើយដល់ពេលក្រោយមកអង្គការចាប់ទៅ ឬក៏?

ផល ៖ អង្គការយកទៅបាត់ទៅ ។

វ៉ាស៊ី ៖ អង្គការនឹងគឺអ្នកណា ខាងស្រុក?

ផល ៖ ខាងស្រុកនឹង ចាប់គាត់ញ៉ៅបទៅបាត់ហើយ បានថាគាត់គុំនឹងក្បត់ កាលចាប់គាត់ញ៉ៅបនឹងគាត់គុំនឹងនៅ ។

វ៉ាស៊ី ៖ ចឹងអ្នកដែលចាប់ញ៉ៅបនឹង អាចថាគុំនឹង ឬក៏អ្នកផ្សេងទៀត យាយបូ ឬតាទិតអី?

ផល ៖ គាត់គុំ ទាំងអស់ ទាំង៣នឹង ។

វ៉ាស៊ី ៖ ហើយចុះពេលដែលចាប់គុំទៅ?

ផល ៖ អត់ដឹងទេ ចាប់គាត់គុំនឹងអត់ដឹងទេ ខ្ញុំដឹងតែចាប់គាត់ញ៉ៅបនឹងយកទៅកន្លែងគាត់គុំ ។

វ៉ាស៊ី ៖ ប៉ុន្តែអ៊ំមានប្រសាសន៍មិញថា ក្រោយមកគេថាគុំនឹងក្បត់?

ផល ៖ ចា៎! បើបាត់ទៅ ក្បត់នឹង ក៏ខ្ញុំមិនដឹងថាគេយកទៅណាៗ ប៉ុនគ្រាន់គេថាក្បត់ ដឹងថាគាត់គុំនឹងក្បត់ហើយ ។

រ៉ាស៊ី ៖ ហើយចុះយាយបូ តាទិតដែលនៅខាងក្រោមរបស់គុំ?

ផល ៖ ក្បត់រៀបរត់នឹងទៅ ។

រ៉ាស៊ី ៖ ជិតបែកនេះហើយទេ?

ផល ៖ ចា៎!

រ៉ាស៊ី ៖ ចុះពេលដែលគេចាប់ញ៉ៀបហ្នឹងទៅ តើគណៈឃុំថ្មីមកជំនួសបុក៏?

ផល ៖ មកៗពីត្រាំកក់ដែរ ។

រ៉ាស៊ី ៖ ឈ្មោះអីដែរ?

ផល ៖ ឈ្មោះតាប៉ោះៗ ងាប់អស់ហើយ ចាស់ៗអស់ទៅហើយ ។

រ៉ាស៊ី ៖ ឥឡូវស្លាប់អស់ហើយ?

ផល ៖ ដឹងស្លាប់ហើយនៅ មិនដែលដឹង ដែរឃើញ ។

រ៉ាស៊ី ៖ ប៉ុននៅខាងក្រោម នៅអឹងដែល ជាមួយនឹងតាសារូ?

ផល ៖ តាសារូ ។

រ៉ាស៊ី ៖ តាសារូ គាត់នៅនេះ?

ផល ៖ ចា៎!

រ៉ាស៊ី ៖ (តាសារូ មានជម្ងឺរបេង) ចុះ៧៧ដែលខាង.... កាលនឹងនៅក្នុងប្រទេសយើងមានកើតចលាចល ខាងបូព៌ាគេចោទថាក្បត់អីចឹង ហើយខាងពាយ័ព្យនេះ ក៏មានចាប់មេភូមិភាគមេអីខ្លះ ចឹងនៅក្នុងឃុំកំពែងមានរឿងអីកើតឡើង?

ផល ៖ ក្នុងកំពែងនឹងគ្មានស្អី មានតែតាញ៉ៀបក្បត់ មានស្រីនឹង ។

រ៉ាស៊ី ៖ មានតែប៉ុននឹងកើតឡើង?

ផល ៖ ចា៎! មានតែប៉ុននឹង ។

រ៉ាស៊ី ៖ ចុះចំពោះប្រជាជនវិញ ខ្ញុំសួរនៅខាងកំពែង គេថាមានការជម្លៀសប្រជាជនចាស់ឲ្យទៅនៅ១០៩ ប្រជាជនថ្មីឲ្យទៅនៅ១០៥ អានឹងយ៉ាងម៉េចទៅអ៊ំ?

ផល ៖ អូ! ទៅនៅ១០៨ ។

រ៉ាស៊ី ៖ នេះស្រុក១០៩?

ផល ៖ ចា៎! ១០៩ទៅ១០៨ ។

រ៉ាស៊ី ៖ ចឹងម៉េចអ៊ំ អ៊ំជួយប្រាប់គិចមើល ដូចថាប្រជាជនចាស់គេឲ្យទៅ១០៨ ដល់ប្រជាជនថ្មីទៅ១០៥ អានឹងម៉េចដែរ?

ផល ៖ អានឹងខ្ញុំលែងសួរដឹង ខាងជម្លៀសទៅ១០៨ ១០៩នឹង ដូចមិនសួរចាំម៉េចដឹង ។

វ៉ាស៊ី ៖ អត់សួរចាំ?

ផល ៖ ចា៎!

វ៉ាស៊ី ៖ ប៉ុន្តែមានមែន?

ផល ៖ ចា៎! មាន ។

វ៉ាស៊ី ៖ ហើយចុះរឿងដូចថាគេយកខាងខ្មែរកម្ពុជាក្រោមយកមកដាក់នេះ នៅឆ្នាំណាដែរ?

ផល ៖ កម្ពុជាក្រោមមកដាក់នឹងដូច៧៧ដែរ ហើយ៧៨ហើយ ឲ្យកម្ពុជាក្រោមនឹង ខ្ញុំដូចមិនចាំឆ្នាំដែរ ។

វ៉ាស៊ី ៖ មានគ្នាប្រហែលជាប៉ុន្មាននាក់ទៅ កម្ពុជាក្រោម?

ផល ៖ ច្រើនដែរ ប៉ុនដឹងប៉ុន្មានរយ ច្រើនភូមិដែរមកនឹង ។

វ៉ាស៊ី ៖ ពួកនឹងមកពីខាងណាវិញ?

ផល ៖ ខាងកម្ពុជាក្រោម ស្អីតាំងពីត្រាក់ ថៅកែឌុចៗស្អីៗខ្ញុំភ្លេចអស់ហើយ ខ្ញុំមិនចាំ ។

វ៉ាស៊ី ៖ ហ្នឹងអង្គការគេឲ្យមកយ៉ាងម៉េច?

ផល ៖ អង្គការគេជម្លៀសមកៗកាល៧៧ចឹងហើយ វ៉ៃៗចូលដល់ស្រុកយួននោះដល់៧៧ ។

វ៉ាស៊ី ៖ វ៉ៃចូលខាងណាវ៉ៃចូល?

ផល ៖ កងទ័ពៗ ។

វ៉ាស៊ី ៖ ចឹងពួកនឹងមកដើម្បីអីដែរ មកនៅក្នុងឃុំគោកព្រេច?

ផល ៖ នៅគោកព្រេច នៅ ។

វ៉ាស៊ី ៖ នៅគោកព្រេចមានដែរ ហើយនៅកំពែងមានដែរ?

ផល ៖ មាននៅគ្រប់ ។

វ៉ាស៊ី ៖ មូលហេតុអីបានគេនាំមកនឹង?

ផល ៖ គេដកចេញមក ថាវ៉ៃបែកកុំឲ្យនៅជាមួយយួន កាលនឹង ។

វ៉ាស៊ី ៖ គេប្រាប់មូលហេតុថាចឹង?

ផល ៖ ចា៎! គេដកជម្លៀសមក កុំឲ្យយួនកាន់កាប់ ។

វ៉ាស៊ី ៖ ហើយចុះឡូះប្រជាជនយើងដែលនៅក្នុងភូមិ ដូចថាដែលនៅពីមុនមក?

ផល ៖ អានឹងគេឲ្យទៅកោះអណ្តែតទៅ ។

វ៉ាស៊ី ៖ ម៉េចបានគេអត់ឲ្យនៅជាមួយគ្នា?

ផល ៖ ខ្ញុំក៏មិនដឹងដែរ ។

រ៉ាស៊ី ៖ ហើយកាលនឹងអ៊ំនៅគ្រប់គ្រងនឹង មើលទៅដូចថាការគ្រប់គ្រងរវាងប្រជាជនមូលដ្ឋាន ខ្មែរៗគ្នាយើង ហើយនឹងការគ្រប់គ្រងទៅលើខ្មែរកម្ពុជាក្រោមម៉េចដែរ មានការខុសគ្នាម៉េចដែរ?

ផល ៖ វានេះ ឃើញប្លែកស្អីផង រៀងធ្វើការងារៗធ្វើដូចគ្នា ។

រ៉ាស៊ី ៖ ចុះការហូបចុកម៉េចដែរ?

ផល ៖ ហូបតាមរបបគេកំណត់ ។

រ៉ាស៊ី ៖ គេកំណត់ប៉ុន្មាន ម៉ាកំប៉ុងគ្នាប៉ុន្មាននាក់ ឬក៏ម្នាក់ប៉ុន្មានកំប៉ុង?

ផល ៖ ដឹងម៉េច ។

រ៉ាស៊ី ៖ យើងនៅជាសហករណ៍ ឬក៏យើងនៅតាមផ្ទះចឹង?

ផល ៖ កាលនឹងដឹងម៉េចហើយទេ ។

រ៉ាស៊ី ៖ រកនឹកគិត?

ផល ៖ កាលនោះមិនតាមផ្ទះទេ តាមសហករណ៍ដែរនឹង ខ្ញុំរៀងក្មេចៗអស់ហើយ មានរោងសហករណ៍គេដែរ ។

រ៉ាស៊ី ៖ អត់មានដែលអ្នកណាមករំលឹកឃើញដើមវិញចឹង?

ផល ៖ អត់ទេ ខ្ញុំអត់ដែររកនឹកអត់ឃើញ ដល់នឹងដូចជារៀងភ្លេចៗម៉េចដឹង ដល់កន្លែងយកកម្ពុជាក្រោមមកៗដូចជារៀងភ្លេចៗ ។

រ៉ាស៊ី ៖ ហើយចុះក្រោយមកបងប្អូនកម្ពុជាក្រោមយើងទៅណាវិញ ឬក៏ស្លាប់?

ផល ៖ មិនទេ ខ្លះទៅស្រុកគេវិញ ដល់រត់នឹងខ្ញុំអត់ដឹងទេ ដល់ពេលយួនបុកមករត់ទៅលើដឹងជាទៅណាអីណា អត់ដឹងដែរ បែកបាក់គ្នាដឹងទៅណា ។

រ៉ាស៊ី ៖ ហើយកាលនោះអ៊ំនៅនឹងឃុំនឹងដែរតើ?

ផល ៖ នៅនឹងឃុំ ។

រ៉ាស៊ី ៖ ហើយកាលនឹងតាញ៉ែបនឹង គេចាប់បាត់ហើយ ពេលកម្ពុជាក្រោមមកនឹង?

ផល ៖ ទៅបាត់អស់ហើយ ចាំ!កម្ពុជាក្រោមចូលមកនឹង អានឹងចូលដល់តាប៉ោះ ។

រ៉ាស៊ី ៖ ម៉េចដែរតាប៉ោះហើយតាញ៉ែប ការគ្រប់គ្រងដូចថាមួយណាល្អជាង ឬក៏យ៉ាងម៉េច?

ផល ៖ ដូចតែគ្នា ។

រ៉ាស៊ី ៖ តាញ៉ែបនឹងកាចទេ?

ផល ៖ តាញ៉ែបកាចៗ បានខ្ញុំថាកាច កាលនឹងខ្ញុំដើរមិនរួចទេ ជើងខ្ញុំវានៅដើរមិនទាន់រួច ហើយដល់ពេលហៅប្រជាជនប្រជុំ អ៊ីមួយនោះគាត់ពោះធំៗ គាត់ដេកៗស្តាប់គេ ដល់ហើយខ្ញុំក៏មិនសូវដែលបានចូលទៅប្រជុំជាមួយគាត់ញឹកញាប់ ដល់ពេលហៅស្តី ហៅចង្អុរមុខអីចឹងទៅ ដល់ពេលចឹងខ្ញុំក៏មិនហ៊ានថាអីដែរ ខ្ញុំថា ដល់នេះខ្ញុំសួរប្រធាននារី ដល់ពេលស្ងាត់ចេញពីប្រជុំ ខ្ញុំសួរថា«តានឹងដើរប្រជុំរាល់ដង គាត់កាចចឹងដែរអី?» ព្រោះខ្ញុំមិនដែលដើរតាមគាត់ញឹកញាប់ ថាប្រជាជនម្យ៉ាងថាខ្មាំងហើយ តែម្យ៉ាងខ្លាចយើងដែលរត់ទៅតំបន់៣៥ រត់ទៅខេត្តកំពត។ ម្យ៉ាងខ្លាចយើង ម្យ៉ាងថាខ្មាំងបង្កប់ ខ្មាំងបំផុសចលនាឲ្យរត់ហើយ ខ្ញុំគ្រាន់សួរប៉ុននឹង ប្រធាននារីគេរាយការណ៍ឲ្យតាញ៉ែបនឹង មកថាឲ្យខ្ញុំមាំៗដែរ ដល់ពេលតាញ៉ែប គាត់មានស្រីហើយ គាត់ខ្លាចខ្ញុំតាមដានគាត់ ហើយខ្ញុំអត់តាមដាន សួរគេតាមត្រង់ ហើយគាត់ថាខ្ញុំតាមដានគាត់ៗក៏ មានស្រីបែកហូរហែលចឹងទៅខ្ញុំក៏អត់បាននៅ។ ដល់តាប៉ោះគាត់មិនដែលស្តីឲ្យខ្ញុំខ្លាំង មានតែតាញ៉ែបទេ។

វ៉ាស៊ី ៖ ចឹងអ៊ំដែលឃើញតាញ៉ែបនឹង បញ្ជាឲ្យអ្នកណាម្នាក់ចាប់ អ្នកនៅក្នុងភូមិ ហើយយកមកព្រមាន ឬចាប់ដាក់គុកដាក់អីទេ?

ផល ៖ មានៗ ឃើញដែរនឹង មានឃើញចាប់មកៗយកមកដាក់នៅផ្ទះគេនៅនឹងភូមិនឹង។

វ៉ាស៊ី ៖ ចាប់ តាញ៉ែបនឹងបញ្ជា ឬក៏?

ផល ៖ តាញ៉ែបបញ្ជា បើតាញ៉ែបមិនបញ្ជា គ្មានអ្នកណាចាប់ទេ។

វ៉ាស៊ី ៖ ចាប់គ្នាប៉ុន្មាននាក់?

ផល ៖ ២-៣នាក់។

វ៉ាស៊ី ៖ អ្នកដែលគេចាប់មកនឹង ខុសអី បានគេចាប់មក?

ផល ៖ មួយនោះធ្វើការមិនកើត ដូចថាជនជាតិចិន គាត់មិនចេះស្ទូងអីចឹង។ ឲ្យគាត់ស្ទូងគាត់មិនចេះស្ទូង ហើយគាត់ថាគាត់ធ្វើចឹងទៅណា ខាងខ្ជិលធ្វើមិនចេះ។ ហើយមួយនោះដើរហួសសុំគេទៅប៉ុន្មានថ្ងៃ ដល់ហួសថ្ងៃចាប់មក។

វ៉ាស៊ី ៖ ពេលដែលគេចាប់មកនឹង គេមានចងមានអីមកដែរ?

ផល ៖ ដល់នៅលើផ្ទះនឹងមិនឃើញចងទេ។

វ៉ាស៊ី ៖ នៅលើផ្ទះ ផ្ទះនៅត្រង់ណា?

ផល ៖ ភូមិតាម៉េង ឃុំតាម៉េង ខ្ញុំឡើងទៅសួរ មិនឃើញចង ឃើញគេដាក់នៅលើផ្ទះនឹង។

វ៉ាស៊ី : នៅលើផ្ទះនឹង ក្រៅពីអ្នកទាំង៣-៤ដែលចាប់មក មានអ្នកផ្សេងទៀត ដែលជាប់នៅក្នុងនឹងដែរ?

ផល : អត់ឃើញទេ មានតែអ្នកផ្ទះៗ អាកន្លែងគេនៅផ្ទះនឹង ដូចថាសេនាជនគេយកមកនៅនឹង គេអត់ទាន់មានមន្ទីរអីចឹង គេនៅផ្ទះនឹង ហើយយកមកទុកនៅនឹង ។

វ៉ាស៊ី : កងឈ្លប?

ផល : ចា៎!

វ៉ាស៊ី : ហើយចុះក្រោយមក អ្នកទាំងនឹងទៅណា?

ផល : នៅៗរស់ ។

វ៉ាស៊ី : ចុះអ្នកដែលចាប់នឹងឈ្មោះអី?

ផល : ដឹកអ្នកណាគេ អ្នកទៅចាប់ ។

វ៉ាស៊ី : កាលចាប់នឹង កាលនឹងមានបែងចែកជាប្រធានកងឈ្លប ប្រធានជាអី?

ផល : កងឈ្លប គេច្រើនឲ្យទៅចាប់ៗ ឈ្មោះអីៗ ខ្ញុំមិនដឹងទេ ខ្ញុំទៅឃើញដំបូងបង្អស់ ឃើញគេចាប់មកនៅលើផ្ទះនឹង ខ្ញុំបានទៅចូលសួរដែរ ។

វ៉ាស៊ី : នៅឆ្នាំណា?

ផល : ៧៤ ។

វ៉ាស៊ី : ចុះ៧៥ ៧៦ ៧៧នេះ មានទេ?

ផល : មិនឃើញទេ អានឹងបើគេចាប់ គេត្រូវដើរធ្វើការ អានឹងខ្ញុំអត់ដឹង អានឹងគេត្រូវសំរិតសំរាំងអី អានឹងខ្ញុំលែងដឹងហើយ អត់ដឹងគេផ្នែកដូចខាងប្រធានៗនឹង ព្រោះខ្ញុំអត់ដើរ ។

វ៉ាស៊ី : ចុះពេលគេចាប់ញ៉ៀបទៅនឹង អ៊ំឃើញទេ?

ផល : ឃើញ ។

វ៉ាស៊ី : គេចាប់ម៉ោងប៉ុន្មាន?

ផល : ទម្រាំចាប់គាញ៉ៀបនឹងបាន យូរថ្ងៃ គាត់មានកាំភ្លើង គាត់ចេញទៅពួននៅភូមិពោធិ៍បាយនឹង យូរថ្ងៃណាស់ ទម្រាំចាប់បានៗ ដល់ពេលចេញទៅដុះអាចម៍អត់យកកាំភ្លើងទៅបាន គេព័ទ្ធចាប់បាន ។

វ៉ាស៊ី : នៅប្រហែលជាម៉ោងប៉ុន្មាន?

ផល : ដឹងម៉ោងប៉ុន្មាន ភ្លេច ។

វ៉ាស៊ី : អ្នកណាអ្នកមកចាប់គាត់នឹង?

ផល ៖ ឈ្លប កងស្រុកគេ ខ្ញុំមិនស្គាល់ កងស្រុកគេមកចាប់ ។

រ៉ាស៊ី ៖ អត់ស្គាល់ឈ្មោះដែរ?

ផល ៖ ចា៎! នាំកងស្រុក ។

រ៉ាស៊ី ៖ គ្នាប៉ុន្មាននាក់មកចាប់?

ផល ៖ មិនដឹងប៉ុន្មាននាក់ ។

រ៉ាស៊ី ៖ ចុះអ៊ីចឹងថាឃើញ គេមកចាប់?

ផល ៖ គេមកចាប់ ព័ទ្ធចាប់នឹងមិនដឹងប៉ុន្មាននាក់ទេ ប៉ុនគេចាប់បានទៅ ខ្ញុំក៏បានឃើញដែរ ។

រ៉ាស៊ី ៖ គេចងគាត់ដែរ?

ផល ៖ ពីនេះទៅអត់ចងទេ ទៅតាមសំរួលអត់ចងអត់អី ទៅដល់កន្លែងស្រុក មិនដឹងគេម៉េចពីនេះទៅគេអត់ចង ។

រ៉ាស៊ី ៖ ហើយម៉េចបានដឹងថាគេសម្លាប់គាត់?

ផល ៖ អត់ដឹងទេ សម្លាប់គេយកទៅណាហើយខ្ញុំក៏មិនដឹង ទៅពីស្រុកទៅ ។ ទៅដល់ស្រុកនឹង ដឹងគេយកទៅណាទៀត ខ្ញុំក៏មិនដឹងដែរ ។

រ៉ាស៊ី ៖ ស្រាប់តែបាត់ឈឹងរហូតទល់ឥឡូវ?

ផល ៖ ចា៎!

រ៉ាស៊ី ៖ ចុះខាងស្រុក គេថាធម្មតាយើងនៅក្នុងឃុំនេះ នៅក្រោមបញ្ជាផ្ទាល់របស់ស្រុក ដល់ខាងស្រុកគេដាក់ផែនការអីខ្លះមកឲ្យខាងឃុំជាអ្នកអនុវត្ត?

ផល ៖ ផែនការគេ វាមិនតាមរដូវ តាមពេល តាមវេលា គេជ្រើសរើសកងទ័ពអីចឹងទៅ ។

រ៉ាស៊ី ៖ មានជ្រើសរើសកងទ័ពអីដែរ?

ផល ៖ ចា៎!

រ៉ាស៊ី ៖ ខាងស្រុកគេដាក់បញ្ជាមកចឹង?

ផល ៖ ចា៎! រើសកងទ័ព រើសពង្រឹងសហករណ៍គេ ។

រ៉ាស៊ី ៖ នៅឆ្នាំណាដែរអ៊ំ ដែលគេជ្រើសរើសកងទ័ព?

ផល ៖ ជ្រើសរើសកងទ័ព រាល់តែឆ្នាំ ពេល ។

រ៉ាស៊ី ៖ ហើយមានអ្នកស្ម័គ្រចិត្តចូល ឬក៏គេបង្ខំឲ្យចូល?

ផល ៖ រឿងស្ម័គ្រចិត្តវាមិនសូវមាន ស្រេចតែគេត្រូវការ ។

រ៉ាស៊ី ៖ គេចុចឈ្មោះពីលើមក?

ផល ៖ ចាំ! ស្រេចតែគេត្រូវការ ។

រ៉ាស៊ី ៖ ចុះខាងស្រុកគេបញ្ជូនឈ្មោះមក ឬក៏យើងខាងឃុំជាអ្នកចុចឈ្មោះឲ្យទៅ?

ផល ៖ ខាងឃុំជ្រើសរើស ។

រ៉ាស៊ី ៖ ហើយអ្នកដែលត្រូវជ្រើសរើសនឹង គេពេញចិត្តឲ្យទៅ ឬក៏គេមិនសូវជាពេញចិត្តប៉ុន្មានទេ?

ផល ៖ ខ្លះក៏ពេញចិត្ត ខ្លះក៏គេចង់ទៅចឹងទៅ ខ្លះទៅទាំងបង្ខំ ស្រេចតែគេដាក់ចឹងទៅ បើមិនទៅយើងនឹងមិនដើរតាមមាគ៌ាគេ ។

រ៉ាស៊ី ៖ មានរឿងអីខ្លះកើតឡើងទៅ បើសិនជាអត់ដើរតាមមាគ៌ាគេ?

ផល ៖ តែមិនដើរតាមមាគ៌ាគេ នឹងគេយកទៅរៀនសូត្រ ហើយគេយកទៅណាអី ។

រ៉ាស៊ី ៖ គេមានប្រើពាក្យរៀនសូត្រចឹងដែរ?

ផល ៖ ចាំ!

រ៉ាស៊ី ៖ ហើយដូចថាខាងគណៈឃុំនឹង ដែលមានប្រើពាក្យរៀនសូត្រនឹង ទៅខាងប្រធានកងប្រធានសហករណ៍ ឧទាហរណ៍ថាឥឡូវប្រជុំអីមួយចឹង ស្រាប់តែប្រកាសថា បើសិនជាមិនធ្វើតាមការណែនាំនេះ នឹងហៅរៀនសូត្រ មានដែលនិយាយចឹង?

ផល ៖ ប្រជុំថាចឹងដែរ ។

រ៉ាស៊ី ៖ ហើយអ៊ំដឹងថារៀនសូត្រនឹង គេយកទៅណា?

ផល ៖ អារៀនសូត្រគេយកទៅណា ខ្ញុំក៏មិនដឹង ហើយបើថារៀនសូត្រៗចឹងទៅ គិតតែរៀនសូត្រនឹងគេចឹងទៅ ។

រ៉ាស៊ី ៖ ហើយអ៊ំនៅនឹងរហូតទាល់តែបែក៧៩ម៉ង?

ផល ៖ ដល់រត់ យើងនាំគ្នាយួនចូលមកទៅទាំងអស់គ្នា ។

រ៉ាស៊ី ៖ ទៅណាអ៊ំ?

ផល ៖ ចេះរត់ទៅលើៗ គេឲ្យទៅលើ ចេះទៅ ។

រ៉ាស៊ី ៖ ទៅលើនឹងទៅខាងស្រុក?

ផល ៖ ទៅខាងស្រុកត្រាំកក់ ទៅខាងអីណាទៅ ។

រ៉ាស៊ី ៖ ហើយអ៊ំទៅដល់ណាទៅ?

ផល ៖ ខ្ញុំទៅដល់ស្រុកស្អីទេ ស្រុកកំពង់ឆ្នាំង ទៅដល់ឆ្ងាយណាស់ ដល់ពេលគេឲ្យទៅៗគទៅទៀតខ្ញុំលែងទៅ គេឲ្យទៅអីណា ឆ្ងងទៅណាៗខ្ញុំលែងទៅ ។

វ៉ាស៊ី ៖ ហើយពេលទៅតាមផ្លូវនឹង មានជួបអ្នកធំៗកាលពីជំនាន់ប៉ុលពត អ្នកណាខ្លះ?

ផល ៖ គ្មានជួបទេ អត់ដែលជួបៗ ដូចថាជួបពួកគណៈស្រុកគេចឹង គេមិនទាន់ឆ្លងទៅណារួច គេនៅគៀងទៅតាមគេចឹង ដល់ទៅតាមគេៗដល់ពេលគេឲ្យទៅទៀត ខ្ញុំថាខ្ញុំមិនទៅ លែងទៅកាត់ព្រៃកាត់ផ្សែង ខ្ញុំវែកអន្ទរវែកអីដើរវែកមិនរួច ខ្ញុំមិនទៅ ហើយវិលវិញៗ ខ្ញុំនឹកឃើញថា ឲ្យខ្ញុំទៅ ឲ្យខ្ញុំទៅខ្ញុំមិនដឹងទៅងាប់ណា បើអស់អន្ទរ អស់អំបិលនឹងខ្លួនដឹងទៅឯណា ពីងស្អីណាៗ

វ៉ាស៊ី ៖ ចឹងអ៊ំត្រឡប់មកវិញ?

ផល ៖ ចាំ! ត្រឡប់មកវិញមកៗ

វ៉ាស៊ី ៖ មកស្រុកកំណើតនេះផ្ទាល់ម៉ង ឬក៏?

ផល ៖ ចាំ! មកដល់ៗ

វ៉ាស៊ី ៖ ឆ្នាំណាអ៊ំមកដល់នេះ?

ផល ៖ ខ្ទង់៧០ប៉ុន្មាន រត់បានតិច ៧៨នឹងៗ

វ៉ាស៊ី ៖ ៧៨?

ផល ៖ ចាំ! ៧៨ ៧៩ៗ

វ៉ាស៊ី ៖ រំដោះ៧ មករា ៧៩ នៅក្នុង៧៩ដដែលនឹង?

ផល ៖ ចាំ!

វ៉ាស៊ី ៖ ហើយមកវិញនៅក្នុងភូមិនេះអត់អី អត់មានរឿងកើតឡើងចំពោះអ៊ំ ឬក៏មានប្រជាជនរស់នៅធម្មតាអីចឹងដែរ ឬក៏យ៉ាងម៉េច?

ផល ៖ មានប្រជាជនរស់នៅធម្មតា ធម្មតាយើងអ្នកធ្វើការជំនាន់នឹងក៏គេស្អប់តិចៗ

វ៉ាស៊ី ៖ ម៉េចបានគេស្អប់ បើអ៊ំអត់ធ្វើស្អីតិច?

ផល ៖ យើងមិនដែលធ្វើស្អី ឲ្យតែយើងឈ្មោះថាយើងធ្លាប់ធ្វើការជំនាន់នឹង គេស្អប់ចឹង ត្រង់តែស្អប់តិចស្អប់ច្រើន មិនដឹងចៀសមិនរួចរឿងគេស្អប់ៗ

វ៉ាស៊ី ៖ ចុះមានដូចថាប្រជាជនយើងក្រោយរំដោះ៧៩នឹង មានដូចថាសងសឹកទៅលើខាងកម្មាភិបាលខ្មែរក្រហមវិញ ដូចថាសម្លាប់ ដោយសារអ្នកនឹងកាចសាហាវ?

ផល ៖ មានតែពួកអាធ្លាប់ធ្វើការនៅនឹងចុះមក គេដេញវ៉ៃដែរៗ

វ៉ាស៊ី ៖ ស្គាល់ឈ្មោះទេអ៊ំ ឈ្មោះអីគេ?

ផល ៖ ឈ្មោះគេដេញ ឈ្មោះ តាណៃៗនៅណាខ្លះ គេដេញៗ

វ៉ាស៊ី ៖ គាត់ធ្វើអីខុសបានគេដេញវ៉ៃគាត់?

ផល ៖ គាត់ធ្វើប្រធានឃុំនៅនឹង ហើយគាត់ចុះមកចន្លោះនឹង ខ្ញុំដឹងតែតាណៃ តាសុខ អត់ដឹងមកទេ ។

វ៉ាស៊ី ៖ ប្រធានឃុំគោកព្រេចនឹង?

ផល ៖ ចា៎! កាលនឹងគេដេញវ៉ៃ ។

វ៉ាស៊ី ៖ ហើយរត់ទៅណា?

ផល ៖ ដល់ហើយប្រធានភូមិថ្មីការពារ ។

វ៉ាស៊ី ៖ គាត់រស់នៅដល់សព្វថ្ងៃ?

ផល ៖ មិនដឹងនៅ ហើយមិននៅ ស្រុកគាត់ស្រុកត្រាំកក់ ដឹងគាត់នៅរស់ ឬស្លាប់ហើយ ។

វ៉ាស៊ី ៖ ខ្ញុំចង់សួរតាតុំ ដែលគេចោទថាក្បត់នឹង ដល់ពេលហើយទៅមានអ្នកមកជំនួសគាត់ តាតុំគណៈស្រុកគីរីវង់?

ផល ៖ មាន បាត់តាតុំនឹងទៅ មានអ្នកមកទៀត មកនឹងមិនដឹងស្រុកណា ឈ្មោះស្អីទេ ខ្ញុំមិនចាំដូចឈ្មោះតាយ៉ានចឹងមិនដឹង មានមក ប៉ុនដឹងមកពីស្រុកណា មានមកជំនួស ។

វ៉ាស៊ី ៖ ហើយចុះយាយបូនឹងមានអ្នកមកជំនួសគាត់?

ផល ៖ យាយបូនឹង ចេញទៅបាត់ទៅឈ្មោះយាយឿន ។

វ៉ាស៊ី ៖ យាយឿនដែលថា ប្រធាននារីតំបន់មកជំនួសវិញ?

ផល ៖ ចា៎! មកជំនួសវិញ ។

វ៉ាស៊ី ៖ យាយបូ គាត់ទៅណា គេដកគាត់ចេញ?

ផល ៖ មិនដឹង ខ្ញុំអត់ដឹង ។

វ៉ាស៊ី ៖ គេដកគាត់ចេញ ឬក៏គាត់ផ្លាស់ចេញ?

ផល ៖ មិនដឹងជាផ្លាស់ ហើយក៏គេម៉េច ការងារថ្នាក់ខាងលើ ខ្ញុំអត់ដឹង ។

វ៉ាស៊ី ៖ យាយបូនេះ គាត់ទៅកាន់គណៈកៀនស្វាយ ពេលចេញពីនេះវិញ ។ ហើយតាទិតនេះខ្ញុំអត់ដឹងម៉េចដែរ តាទិត គាត់នៅនឹងរហូត ឬគេដូរគាត់ដែរ?

ផល ៖ នៅនេះ ដូរឈ្មោះតាយ៉ាន មកកាន់កាប់ ប៉ុនអត់ដឹងស្រុកណា ។

វ៉ាស៊ី ៖ ហ្នឹងនៅឆ្នាំ៧៧ ៧៨នឹង?

ផល ៖ ចា៎!

វ៉ាស៊ី ៖ គេចោទថាក្បត់នេះ នៅឆ្នាំ៧០ប៉ុន្មាន តាតុំ?

ផល ៖ គាត់ំនេះ ប៉ុន៧/៧ដឹង ចុង៧/៧ ។

រ៉ាស៊ី ៖ អ៊ំអត់ដឹងមូលហេតុអីគេចោទថាក្បត់?

ផល ៖ ខ្ញុំអត់ដឹង គ្រាន់ដឹងថាជំនាន់ដែលគេថាតស៊ូចេញពីជំនាន់ខ្មែរក្រហមដើរស៊ីស្លឹកឈើ ស្លឹកព្រៃនៅភ្នំនៅអីនឹង ឲ្យតែតស៊ូជំនាន់នឹង គេថាក្បត់ទាំងអស់ កាលនឹង ខ្ញុំមិនដឹងរឿងហេតុក្បត់នឹងដោយមូលហេតុអី ក៏ខ្ញុំមិនដឹង ប៉ុនគេថាក្បត់ៗចឹង ។ សូម្បីតែប្រធានយុវនារីស្រុកនឹងក៏គេដកហូតទៅដែរ ខ្សែរយៈថាឪនឹងមកតស៊ូតាំងពីជំនាន់នៅក្នុងព្រៃនឹងមក ក៏គេដកទៅដែរ ប៉ុនត្រង់គេថាក្បត់ពីព្រោះអីៗក៏ខ្ញុំមិនដឹង ។

វិសាល ៖ អ៊ំមិញមានប្រសាសន៍ថា បន្ទាប់ពីរបបខ្មែរក្រហមដួលរលំទៅ អ៊ំបានត្រឡប់មកភូមិកំណើតវិញ ។ ហើយចឹងទៅអ៊ំថាមានអ្នកស្អប់ដែរ អ៊ំមានប្រសាសន៍ថា គ្រាន់តែដឹងថាយើងធ្លាប់ធ្វើការបម្រើខ្មែរក្រហមនឹង អ៊ំដឹងថាគេស្អប់អីចឹង ។ តើដូចថាអាការដែលគេស្អប់គុំគួននឹង គេមានបញ្ចេញជាអាការៈជាទង្វើរដាក់អ៊ំទេ ឬក៏អត់មានទេ ឬក៏មិនធ្វើចំពោះអ៊ំ ឬអាចមានធ្វើចំពោះអ្នកផ្សេង?

ផល ៖ ចំពោះខ្ញុំ រឿងមាត់ ជាពាក្យ ជាសម្ដីអីមានហើយ ប៉ុនឲ្យសកម្មភាពអីឲ្យខ្លាំងខ្លាអត់មាន ។

វិសាល ៖ គេប្រើពាក្យសម្ដីដាក់អ៊ំដែរ?

ផល ៖ ចា៎!

វិសាល ៖ អ្នកគេប្រើពាក្យសម្ដីដាក់អ៊ំ គាត់ជាអ្នកភូមិមូលដ្ឋានទេ ឬក៏អ្នក?

ផល ៖ អ្នកមូលដ្ឋាន ។

វិសាល ៖ គេប្រើពាក្យសម្ដី?

ផល ៖ គ្រាន់ពាក្យជាសម្ដី ។

វិសាល ៖ អ៊ំធ្លាប់ធ្វើការឲ្យបម្រើបដិវត្ត ក្រោយពីបម្រើបដិវត្តត្រឡប់ទៅក្រោយ គិតរឿងក្រោយៗ មានអារម្មណ៍យ៉ាងណាដែរ?

ផល ៖ អត់មានអារម្មណ៍យ៉ាងណាទេ គិតរឿងធ្វើការរកស៊ីចិញ្ចឹមជីវិត ចិញ្ចឹមខ្លួនដូចគេដូចឯង ។

វិសាល ៖ មានអារម្មណ៍ស្ដាយក្រោយដែលបានធ្វើការនោះ?

ផល ៖ អត់ៗទេ ព្រោះយើងធ្វើការមកយើងខំ តាមពាក្យគេអប់រំណែនាំឲ្យយើងខំធ្វើការលះបង់ការតស៊ូ លះបង់អីចឹង យើងធ្វើទៅយើងអត់មានបានផលប្រយោជន៍អី ទីចុងបំផុតយើងត្រឡប់មករកស៊ីខ្លួនឯងវិញដដែល ។

វិសាល ៖ ធ្វើការឲ្យគេ ចុងក្រោយអត់មានបានអីមកវិញ ចុងក្រោយនៅចាប់ផ្ដើមមកវិញដំបូង ដដែលនឹង នៅអត់ស្គាល់ក្រោយទៀត?

ផល ៖ អត់ ។

វិសាល ៖ ចង់សុំសួរអ៊ីដែលពូរឿងតុលាការកាត់ទោសពួកមេដឹកនាំខ្មែរក្រហម?

ផល ៖ ពូដែរ ។

វិសាល ៖ ពូនឹង ពូតាំងពីពេលណាមក?

ផល ៖ ពូតាមវ៉ាដ្យូផ្សាយសឹងរាល់ថ្ងៃ ។

វិសាល ៖ តាំងពីពូមក ពូអីខ្លះ ដឹងប៉ុនណា អាចជួយសុំជម្រាប?

ផល ៖ ពូកាត់ៗ ដឹងតែថាកាត់ទោសៗ មិនដឹងកាត់ទោសរបៀបម៉េច ។

វិសាល ៖ ពូនឹង ពូយូរនៅ?

ផល ៖ ពូចេះហូរហែលរៀងរាល់ខែ ស្ដាប់វ៉ាដ្យូ ។

វិសាល ៖ ពូនឹងអ៊ំបើកចំ ឬមានចិត្តតាម?

ផល ៖ បើកចំវាពូចឹងទៅស្ដាប់ទៅ ពូថាកាត់ទោសៗ ប៉ុនមិនដឹងកាត់ទោស ។

វិសាល ៖ មានដឹងថាគេកាត់ទោសពីណាខ្លះ?

ផល ៖ នួន ជា, ស្អីណាតាម៉ុកតាអី ខ្ញុំមិនចាំ ។

វិសាល ៖ ក្រៅពីដឹងប៉ុននឹង ដឹងប៉ុនណាទៀត?

ផល ៖ មិនដឹង ដឹងពូតែគេថាកាត់ទោសៗរបៀបម៉េចអីម៉េច កាត់ទោសយូរហើយ មិនទាន់កាត់បាន ។

វិសាល ៖ ពេលដឹងថាមានតុលាការគេកាត់ទោសនេះចឹង ក្នុងចិត្តអ៊ំមានអារម្មណ៍រីករាយត្រេកអរទេ ឬក៏មានអារម្មណ៍ម៉េចដែរអ៊ំ ឬក៏?

ផល ៖ កាត់ទោសអ្នកធំៗ អានេះខ្ញុំ បើថាមានអារម្មណ៍រីករាយ ឬអារម្មណ៍ស្អប់ខ្ចីមក៏វាអត់មានដែល ប៉ុនគ្រាន់ថា ក្នុងចិត្តខ្ញុំនឹកឃើញថា ព្រោះខ្ញុំធ្លាប់ធ្វើការតាមបញ្ជាគេ ក្រែងគេនឹងគេធ្វើតាមបញ្ជាគេពីលើដែរទៅ ប៉ុនគ្រាន់ស្ដាប់បានអាពូចឹង អារឿងអរ រឿងសប្បាយរឿងកាត់ទោសនឹងវាអត់មាន ។ នៅពិចារណាថាយើង គេខាងលើនឹង ក៏មិនដឹងគេធ្វើតាមបញ្ជាគេដែរ ហើយយ៉ាងម៉េចអីចឹង ហើយក៏គេធ្វើចេញពីគំនិតគេ ព្រោះអីយើងមិនដឹងម្ល៉េះហើយអរក៏យើងមិនអរ ។

វិសាល ៖ ចុះភ័យទេ?

ផល ៖ ភ័យក៏មិនភ័យ ។

វិសាល ៖ ដែលនិយាយរឿងប្រាប់ទៅកូនចៅក្មេងៗជំនាន់ក្រោយ?

ផល ៖ ខ្ញុំអត់ដែលនិយាយទេ ។

វិសាល ៖ អត់សោះតែម្តង?

ផល ៖ ចា៎!

វិសាល ៖ មូលហេតុអីបានអត់ដែលនិយាយរឿងនឹងប្រាប់ក្មេងៗនឹង?

ផល ៖ វាអត់មានរឿងត្រូវនិយាយៗ ។

វិសាល ៖ អ៊ំអត់ដែលប្រាប់ ចុះគាត់អត់ដែលសួរអ៊ំទេ អ៊ំអត់ដែលប្រាប់ចឹង?

ផល ៖ អឺ! ដូចជាមិនដែលទាក់ទងរឿងសួរប្រវត្តិសាស្ត្រ ប្រវត្តិអីចឹង ។

វិសាល ៖ ចឹងខ្ញុំសុំអរគុណអ៊ំច្រើន ។

ភ៉ាស៊ី ៖ ហើយរឿងរ៉ាវដែលខ្ញុំសម្ភាសន៍អ៊ំនេះ ខ្ញុំយកទៅសរសេរសាច់រឿងមួយសម្រាប់ក្មេងវារៀង ចឹងសុំការអនុញ្ញាតិពីអ៊ំដែរ អត់អីទេអ៊ំ?

ផល ៖ ចា៎! អត់អី គ្រាន់ខ្ញុំដឹងវាមិនសូវស្ទាត់ ចាំវាមិនសូវអស់ ចាំខ្លះ ភ្លេចខ្លះ ។

វិសាល ៖ អ៊ំចុងក្រោយ អ៊ំមានឯកសារ សៀវភៅសេសសល់ពីសម័យខ្មែរក្រហម របស់អីក៏ដោយ អ៊ំមានសេសសល់មកដល់ឥឡូវ វាអាចថាជាសៀវភៅ ជាអីក៏ដោយឲ្យតែរបស់សល់ពីសម័យនោះ អ៊ំមានទេ?

ផល ៖ អត់មាន ជំនាន់នឹងគ្មានរូបថតទេ ដេកពេទ្យនោះគ្មានទេ ទៅតែដេកពេទ្យចេញមក គ្មានសំបុត្រគ្មានស្នាមអីទេ ។

គន្ធី ៖ ពេទ្យគេអត់មានសំបុត្រចេញស្នាមឲ្យអ្នកជម្ងឺចេញអី?

ផល ៖ អត់ទេ បើថាជាហើយ គេឲ្យចេញចឹងមក អត់មានសំបុត្រ ។

គន្ធី ៖ ចុះលិខិតដែលអ៊ំមានកាន់និរសារអីដែរ កាលនឹងអ៊ំថាមានបញ្ជីស្នាមអី អ៊ំធ្វើការជាមួយ អ៊ំមានបានទុកទេ?

ផល ៖ អត់ ។

វិសាល ៖ របស់នឹង មានដឹងថាមានពីណាអ្នកកាន់ទុករបស់នឹង ឯកសារអីនឹង?

ផល ៖ ឯកសារ មានតែថ្នាក់លើៗ គេបែកឲ្យមើល បែកអីចឹងទៅ ។

គន្ធី ៖ អ្នកណាគេអ្នកទុកដាក់?

ផល ៖ កាលនឹងវាមានកន្លែងទុកដាក់អី ដល់ពេលយើងរត់ទៅ យើងទៅតែខ្លួន មានទុកឯកសារអីទេ ។

ភ៉ាស៊ី ៖ អ៊ំមានអីចង់បន្ថែម ចង់ឆ្លល់ពីអី សួរមកខ្ញុំវិញ កុំឲ្យថាពេលដែលខ្ញុំចេញទៅ អ៊ំមានអារម្មណ៍មួយផ្សេង ភ័យ មានអីឆ្ងល់?

ផល ៖ ខ្ញុំឆ្ងល់ថា ឯងដើរសួរអ្នកធ្លាប់ធ្វើការពីមុនមក ដើរសួរចឹងទៅ កត់រឿង កត់ហេតុអីមានរឿងមានហេតុអីទៅមុខទៀតដឹង?

ភ៉ាស៊ី ៖ អត់មានអីទេអ៊ំ ដូចខ្ញុំជម្រាបចឹងថា មជ្ឈមណ្ឌលឯកសារកម្ពុជានេះ ចង់ក្រងជាឯកសារទុកសម្រាប់ក្មេងៗរៀន ។ ធម្មតាក្មេងៗតូចចេះអត់បានដឹងទេ ពីការងារលំបាក ឬក៏ការងារធ្ងន់ៗ កាលពីជំនាន់ខ្មែរក្រហម ។ បើសិនជាយើងអត់សរសេរទុកទេ ពួកក្មេងៗនឹងអត់ដឹងទេ ។ ហើយឥឡូវនេះ ក្មេងៗដែលចូលថ្នាក់ទី៩នឹងរៀនពីរបបខ្មែរក្រហមអស់ហើយ ចឹងពួកនឹងៗដឹង ។ ហើយខ្ញុំសម្ភាសន៍អ៊ំនេះ គ្រាន់តែចង់ដឹងសាច់រឿងមួយតូចនៅក្នុងរបបខ្មែរក្រហមនឹង ។ ហើយមិនមែនមានតែអ៊ំម្នាក់ទេ មានគ្នាច្រើននាក់ទូទាំងប្រទេសខ្ញុំបានសម្ភាសន៍មនុស្សរាប់ពាន់នាក់រួចហើយ ។ តាំងពីប៉ុន្មានឆ្នាំមុន ៨-១០ឆ្នាំមុន ។ ចឹងអត់មានអីទេ អត់មានថាគេកត់ឈ្មោះដូចកាលជំនាន់ប៉ុលពតកត់ឈ្មោះ យប់ថ្ងៃនឹង ស្អែកឡើងបាត់ខ្លួន អត់ទេ មិនមែនចឹងទេ ។ ចឹងខ្ញុំគ្រាន់ចង់ជម្រាបអ៊ំចឹង កុំឲ្យអ៊ំភ័យ កុំឲ្យអ៊ំព្រួយ ។

វិសាល ៖ អ៊ំអត់ទោសសុំសួរបន្តិចអ៊ំ គេប្រើពាក្យសម្តីដាក់អ៊ំ ពេលបែកប៉ុលពតវិញ គ្រាន់ចង់ដឹងគេប្រើពាក្យម៉េចខ្លះដល់អ៊ំ ពាក្យប្រមាថ ។

ផល ៖ យើងធ្លាប់ធ្វើការ ធ្លាប់សម្លាប់គេ ចេះតែថាទៅយើងធ្លាប់ធ្វើការហើយ ត្រង់យើងសម្លាប់គេ មិនសម្លាប់គេ គេចេះតែថាឲ្យរួចពីមាត់គេទៅ ។ គេអ្នកថាចេះថា ។

វិសាល ៖ ចុះអ៊ំឆ្លើយតបទៅគេថាម៉េច មានប្រតិកម្ម?

ផល ៖ បើយើងអត់ធ្លាប់សម្លាប់ផង ខ្ញុំសួររកអាការសម្លាប់អ្នកណាៗ ។

វិសាល ៖ ឆ្លើយទៅគេៗបាត់មាត់ទៅ?

ផល ៖ ចា៎! សួរសម្លាប់នឹងឈ្មោះអីខ្លះ ធ្លាប់គេងប្រវិញ្ចទ្រព្យរបស់គេ ដល់ហើយខ្ញុំសួរថាយកស្អីខ្លះ ដល់វារកកន្លែងយកមិនឃើញ រកសម្លាប់មិនឃើញក៏នៅស្ងៀមទៅ គេថាខ្ញុំសួរចុងដើមមក ខ្ញុំធ្វើស្អីៗតាមបញ្ជាគេ មិនធ្វើតាមខ្លួនឯងណា ។ ទៅធ្វើការនឹងក៏យើងអត់មាន

ទិញគេ បុណ្យសក្តិដែលធ្វើនឹងក៏អត់មានទិញគេ ។ គេគុំរូងការយើង បើយើងមិនទៅបានន័យថាយើងអត់ដើរតាមគេ ។

វិសាល ៖ អរគុណច្រើន ។

«ចប់»